វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

## ឯកសារស្រាវជ្រាវ

លោកជំទាវឃ្លួន សុដាវី អនុប្រធានទី២នៃវុឌ្ឍសភា

# ការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងកម្ពុជា


**អ្នកនិពន្ធ៖**

បណ្ឌិត **គីម សុធន្ធ** (អ្នកបណ្តុះបណ្តាលជាន់ខ្ពស់-PRCD)

លោកស្រី **រស់ បណ្តែត** (អ្នកបណ្តុះបណ្តាលជាន់ខ្ពស់-PRCD)

លោក Florent P.B. Zwiers (អ្នកបណ្តុះបណ្តាលជាន់ខ្ពស់-PRCD)

លោកស្រី **គីម កែវធីតា** (អ្នកបណ្តុះបណ្តាល-PRCD)


ខែតុលា ឆ្នាំ ២០១៩


ការិយាល័យរបស់វិទ្យាស្ថានសភាកម្ពុជា៖ ផ្ទះលេខ ៣២ ផ្លូវលេខ ៩ សង្កាត់ទន្លេបាសាក់ រាជធានីភ្នំពេញ
និងនៅក្នុងបរិវេណព្រឹទ្ធសភា វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ
+855 (0) 23 210 055/6 | admin@pic.org.kh | www.pic.org.kh

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា(វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការ ផ្តល់នូវឯកសារស្រាវជ្រាវតបតាមសំណើរបស់សមាជិក សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារនេះផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារនេះមានកំណត់កាលបរិច្ឆេទច្បាស់លាស់ ដើម្បីផ្តល់ជាឯកសារជំនួយស្មារតីតបតាមម្ចាស់សំណើ។ ឯកសារនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬគោលនយោបាយណាមួយឡើយ ដោយផ្តោតតែលើព័ត៌មានពីឯកសារដែលមានស្រាប់ និងមិនបានសិក្សាឲ្យគ្រប់ជ្រុងជ្រោយដើម្បីឆ្លើយតបទៅនឹងបញ្ហាលម្អិតនៃការស្រាវជ្រាវនោះទេ ពោលគឺដើម្បីឆ្លើយតបទៅនឹងសំណើដែលទទួលបានតែប៉ុណ្ណោះ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំចងក្រងឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថានសភាកម្ពុជា។

©រក្សាសិទ្ធិ ឆ្នាំ២០១៩ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

## មាតិការ


អក្សរកាត់ ....................................................................................................i

បញ្ជីរាយនាមតារាង......................................................................................iii

បញ្ជីរាយនាមក្រាហ្វិក ....................................................................................iii

សេចក្តីផ្តើម ....................................................................................................1

I. ការបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងវិស័យអប់រំ ........................................2

*១.និន្នាការ និងវឌ្ឍនភាព.............................................................................2*

*១១. អត្រាអក្ខរកម្មជនពេញវ័យ....................................................................2*

១២.. *អត្រាចុះឈ្មោះចូលរៀន.......................................................................3*

*១៣.. អត្រាបោះបង់ការសិក្សា......................................................................4*

*១.៤. ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(TVET) .............................5*

*២. បញ្ហាប្រឈម..........................................................................................6*

*៣ក្របខណ្ឌច្បាប់ និងគោលនយោបាយជាតិ . ....................................................8*

II. ស្ត្រី និងការទទួលបានសេវាលើកកម្ពស់សុខភាពមាតា និងទារក ...........................9

*១បរិបទ...................................................................................................9*

*២. បម្រែបម្រួល និងបច្ចុប្បន្នភាពរបស់ស្ថានភាពសុខភាពមាតា និងទារក......................9*

*៣ការពង្រីកសេវាសុខភាពមាតា និងទារក......................................................10*

*៤ការទទួលបាន និងការប្រើប្រាស់សេវាលើកកម្ពស់សុខភាពមាតា និងទារក . ..............12*

*៥លទ្ធភាពចំណាយសេវាសុខភាពមាតា និងទារក...............................................13*

*៦ក្របខ័ណ្ឌគោលនយោបាយ.........................................................................14*

III.សេដ្ឋកិច្ច ការចូលរួមកម្លាំងពលកម្ម និងភាពជាសហគ្រិនស្ត្រី.................................16

១កម្លាំងពលកម្មកម្ពុជា៖ នៅក្មេងខ្ចី . ហើយត្រូវប្រកួតប្រជែងជាមួយអាស៊ាន ..................16

*២៤បដិវត្តឧស្សាហកម្មលើកទី ...................................................................17*

*៣) ស្ត្រីដល់សេដ្ឋកិច្ចផ្នែកអង់អាចភាពបង្កើន .WEE) ..........................................18*

*៤ជម្រើសគោលនយោបាយ . .........................................................................20*

IV.អំពើហិង្សាលើស្ត្រី..................................................................................21

*១និន្នាការ . និងវឌ្ឍនភាព ..........................................................................23*

*១១.. អាស៊ាន (ASEAN) ..............................................................................23*

*១២.. ប្រទេសកម្ពុជា.....................................................................................24*

*២បញ្ហាប្រឈម . ......................................................................................24*

*៣ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ* . .......... *26*
*៣.១. អាស៊ាន (ASEAN)* .......... *26*
*៣ .២.ប្រទេសកម្ពុជា*.......... *26*
*៣ .៣.គម្លាតគោលយោបាយ*.......... *28*
*៤អ្វីដែលគួរធ្វើបន្ត* .......... *29*
សេចក្តីសន្និដ្ឋាន .......... 30

# អក្សរកាត់

| | |
|---|---|
| ANC | សេវាថែទាំគភ៌មុនសម្រាល |
| ASEAN | សមាគមប្រជាជនអាស៊ីអាគ្នេយ៍ |
| BEmONC | សេវាសង្គ្រោះបន្ទាន់សម្រាប់មាតា និងទារកដែលផ្តល់ដោយបុគ្គលិកពេទ្យជំនាញដើម្បីមរណភាពមាតា និងទារក |
| DV | អំពើហិង្សាក្នុងគ្រួសារ |
| CEDAW | លុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី |
| FTIRM | ផែនទីចង្អុលបង្ហាញសម្រាប់ការកាត់បន្ថយអត្រាមរណៈភាពមាតា និងទារក |
| HEF | មូលនិធិសមធម៌សុខភាព |
| HSP | ផែនការយុទ្ធសាស្ត្រសុខាភិបាល |
| ICT | បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| MMR | អត្រាមរណភាពមាតា |
| MOWA | ក្រសួងកិច្ចការនារី |
| MoI | ក្រសួងមហាផ្ទៃ |
| MoP | ក្រសួងផែនការ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| NSDP | ផែនការយុទ្ធអភិវឌ្ឍន៍ជាតិ |
| OECD | អង្គការសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការសេដ្ឋកិច្ច |
| PISA | កម្មវិធីសម្រាប់វាយតម្លៃសិស្សអន្តរជាតិ |
| PNC | សេវាពិនិត្យក្រោយសម្រាល |
| SDG 3 | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍គោលដៅទី ៣ |
| SDG 4 | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍គោលដៅទី ៤ |
| SDG 5 | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍គោលដៅទី ៥ |
| SDG 9 | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍គោលដៅទី ៩ |
| TVET | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |

| | |
|---|---|
| VAWG | អំពើហិង្សាលើស្ត្រី និងកុមារ |
| WEE | ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី |
| WHO | អង្គការសុខភាពពិភពលោក |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| STEM | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា |
| UNESCAP | គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក |

# បញ្ជីរាយនាមតារាង


តារាង ១៖ ភាគរយស្ត្រីមានផ្ទៃពោះទទួលបានសេវាថែទាំគភ៌មុនសម្រាល (ANC) ........................... 11

តារាង ២៖អត្រានៃការសម្រាលដោយបុគ្គលិកសុខាភិបាល ........................................................ 12

តារាង ៣៖ការទទួលបានសេវាសុខភាពមាតានិងទារកតាមតំបន់ក្នុងប្រទេសកម្ពុជា ........................ 13

តារាង ៤៖ការទទួលបានសេវាសុខភាពមាតា និងទារកតាមប្រភេទកម្រិតជីវភាពក្នុងប្រទេសកម្ពុជា......14

តារាង ៥៖ទិដ្ឋភាពទូទៅនៃភាពជាសហគ្រិនតាមយេនឌ័រ ........................................................ 17


# បញ្ជីរាយនាមក្រាហ្វិក


ក្រាហ្វិកទី១៖ អត្រាអក្ខរកម្មជនពេញវ័យ តាមភេទនៅកម្ពុជា ២០០៨¬-២០១៧ (%) ..................... 2

ក្រាហ្វិកទី២៖ អត្រាអក្ខរកម្មជនពេញវ័យតាមភេទ និងទីតាំងភូមិសាស្ត្រនៅកម្ពុជា២០១៧ (%) .......... 2

ក្រាហ្វិកទី៣៖ អត្រាអក្ខរកម្មជនពេញវ័យរបស់ស្ត្រីតាមប្រទេស២០០៨-២០១៧ (%) ...................... 3

ក្រាហ្វិកទី៤៖ ផលធៀបចុះឈ្មោះចូលរៀនពិត តាមភេទនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សានៅកម្ពុជា ២០០៨-២០១៦ (%) ........................................................................................ 3

ក្រាហ្វិកទី៥៖ ផលធៀបចុះឈ្មោះចូលរៀនពិតរបស់ក្មេងស្រីនៅថ្នាក់មធ្យមសិក្សាតាមបណ្តាប្រទេសនៅអាស៊ាន២០០៨- ២០១៦ (%) ................................................................................ 3

ក្រាហ្វិកទី៦៖ អត្រាចុះឈ្មោះចូលរៀនរបស់ស្ត្រីនិងបុរសនៅថ្នាក់ឧត្តមសិក្សា នៅកម្ពុជា ២០១១- ២០១៦ (%) ........................................................................................................ 4

ក្រាហ្វិកទី៧៖ អត្រាបោះបង់ការសិក្សាថ្នាក់ជាតិ តាមភេទនៅថ្នាក់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ២០០៧-២០១៧ នៅកម្ពុជា (%) ............................................................ 4

ក្រាហ្វិកទី៨៖  អត្រាបោះបង់ការសិក្សាថ្នាក់ជាតិរបស់ក្មេងស្រីតាមទីតាំងភូមិសាស្ត្រនៅថ្នាក់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ២០១១-២០១៧នៅកម្ពុជា (%) ................................. 5

ក្រាហ្វិកទី១០៖ អត្រាចុះឈ្មោះចូលរៀនរបស់ស្ត្រី និងបុរសតាមមុខជំនាញ នៅថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រនៅកម្រិតអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២០១៧-២០១៨ នៅកម្ពុជា ....... 6

ក្រាហ្វិកទី៩៖ អត្រាចុះឈ្មោះចូលរៀន និងអត្រាបោះបង់ការសិក្សាថ្នាក់ជាតិរបស់បុរស និងស្ត្រីនៅកម្រិតអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២០១២-២០១៨ នៅកម្ពុជា (%) ......................... 6

ក្រាហ្វិកទី១១៖ បំរែបំរួលនៃអត្រាមរណភាពមាតាក្នុងទារកកើតរស់១០០ ០០០នាក់ក្នុងប្រទេសអាស៊ានមួយចំនួនចាប់តាំងពីឆ្នាំ ១៩៩០ ..................................................................... 10

ក្រាហ្វិកទី១២៖សមាមាត្រស្ត្រីដែលធ្លាប់រងអំពើហិង្សាលើរាងកាយនិង / ឬអំពើហិង្សាផ្លូវភេទពីដៃគូជិតស្និទ្ធក្នុងជីវិតរបស់ពួកគេ ២០០៣-២០០៧ ............................................................. 23

ក្រាហ្វិកទី១៣៖ សមាមាត្រស្ត្រី និងក្មេងស្រី ដែលបានរងរបួសទាក់ទងនឹងអំពើហិង្សា....................... 23
ក្រាហ្វិកទី១៤៖ សមាមាត្រស្ត្រី និងក្មេងស្រី ដែលបានរងរបួសទាក់ទងនឹងអំពើហិង្សា....................... 24

## សេចក្ដីផ្ដើម

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសកល (SDGs) បានកំណត់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ជាគោលដៅមួយក្នុងចំណោមគោលទាំង១៧ ហើយបានបញ្ជាក់ថាវាជាមធ្យោបាយដ៏មានប្រសិទ្ធភាពដើម្បីបញ្ចប់ភាពក្រីក្រ ការពារភពផែនដី និងធានាថាប្រជាជនទាំងអស់ទទួលបានសន្តិភាព និងវិបុលភាពនៅឆ្នាំ២០៣០[1]។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទីប្រាំ (SDG5) បានបង្កើតឡើងដើម្បី «សម្រេចនូវសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រីទាំងអស់ដោយមិនលើសពីឆ្នាំ២០៣០» តាមរយៈការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី និងក្មេងស្រី[2]។ ការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី គឺជាជំហានដ៏សំខាន់មួយដើម្បីជួយពន្លឿនការអភិវឌ្ឍប្រកបដោយចីរភាពដែលប្រទេសដែលជាសសមាជិកទាំងអស់គួតែតែអនុវត្ត[2]។ ជំហានសំខាន់មួយដើម្បីសម្រេចបានសមភាពយេនឌ័រ គឺការបញ្ចប់រាល់ទម្រង់នៃការរើសអើងលើស្ត្រី ដោយបង្កើនភាពអង់អាចដល់ស្ត្រីតាមរយៈការអប់រំ ការងារ និងភាពជាតំណាងរបស់ស្ត្រីនៅក្នុងនយោបាយ ក៏ដូចជាការធានាឲ្យស្ត្រីទទួលបានសេវាលើកកម្ពស់សុខភាពមាតា និងទារក[3]។

ដើម្បីឆ្លើយតបទៅនឹងគោលដៅទីប្រាំនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG5) រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា ការអភិវឌ្ឍប្រកបដោយចីរភាព និងអភិបាលកិច្ចល្អ ទាមទារឲ្យមានការចូលរួមរបស់ស្ត្រីនៅគ្រប់វិស័យ[4]។ ហេតុដូច្នេះ ការកសាងសមត្ថភាពរបស់ស្ត្រី ដើម្បីឲ្យមានការប្រកួតប្រជែង និងភាពច្នៃប្រឌិតថ្មីនៅក្នុងទីផ្សារការងារ រួមទាំងការលើកកម្ពស់សុខមាលភាពរបស់ស្ត្រី និងក្មេងស្រី គឺជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍនេះ។ ទន្ទឹមនឹងនេះ ដើម្បីផ្តល់នូវព័ត៌មានបន្ថែម និងជាជំនួយដល់ការកសាងសម្ថភាពក្រុមសមាជិកាសភា ក៏ដូចជាក្រុមប្រឹក្សាឃុំ/សង្កាត់ដែលជាស្ត្រី លោកជំទាវឃួន សុដារី អនុប្រធានទី២ នៃរដ្ឋសភា បានស្នើរមកវិទ្យាស្ថានសភាកម្ពុជា ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសក្នុងការរៀបចំឯកសារជំនួយស្មារតី ស្តីពី *«ការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងកម្ពុជា»*។

គោលបំណងសំខាន់របស់ឯកសារនេះគឺផ្តោតសំខាន់លើ និន្នាការសំខាន់ៗ បញ្ហាប្រឈម ច្បាប់ និងនយោបាយដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី។ ជាដំបូង ឯកសារនេះនឹងលើកឡើងពីសារៈសំខាន់ពីការបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងវិស័យអប់រំ ដែលរៀបចំដោយលោកស្រី រស់ បណ្ណែត។ ការទទួលការលើកម្ពស់សេវាសុខភាពមាតា និងទារក មានបង្ហាញជូននៅផ្នែកទី២ ដោយបណ្ឌិត គឹម សុធន្ន។ ផ្នែកសេដ្ឋកិច្ច ការចូលរួមកម្លាំងពលកម្ម និងផ្នែកសហគ្រិនភាពរបស់ស្ត្រី រៀបចំដោយលោក Florent P.B. Zwiers និងផ្នែកអំពើហិង្សាលើស្ត្រី រួមបញ្ចូលទាំងអំពើហិង្សាក្នុងគ្រួសាររៀបចំដោយលោកស្រី គឹម កែវធីតា រួមជាមួយនឹងគោលនយោបាយមួយចំនួនសម្រាប់ទិសដៅទៅមុខ។ ឯកសារស្រាវជ្រាវនេះនឹងផ្តល់ជាការវិភាគទិន្នន័យបែបប្រៀបធៀបរវាងបណ្តាប្រទេសក្នុងតំបន់អាស៊ានមួយចំនួន ឬក៏បណ្តាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបដ៏ទៃទៀត ដែលមានស្ថានភាពប្រហាក់ប្រហែលនឹងប្រទេសកម្ពុជា។

## I. ការបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងវិស័យអប់រំ

ការទទួលបានការអប់រំរបស់ស្ត្រីជាសិទ្ធិមនុស្ស ហើយត្រូវបានកំណត់នៅក្នុងគោលដៅទី៤នៃរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ស្តីពីការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប។ ជាហត្ថលេខីនៃកិច្ចព្រមព្រៀងលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) កម្ពុជាបានព្យាយាមលើកកម្ពស់ភាពអង់អាចដល់ស្ត្រីនៅក្នុងវិស័យអប់រំចាប់តាំងពីឆ្នាំ ២០០៧ តាមរយៈការបញ្ជ្រៀបយេនឌ័រនៅក្នុងគោលនយោបាយ និងផែនការសកម្មភាព វិស័យអប់រំ។ ផ្នែកខាងក្រោមនេះនឹងរៀបរាប់អំពីនិន្នាការ វឌ្ឍនភាព បញ្ហាប្រឈម ច្បាប់និងគោលនយោបាយពាក់ ព័ន្ធនឹងការបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងវិស័យអប់រំនៅកម្ពុជា។

### ១.និន្នាការ និងវឌ្ឍនភាព

#### *១.១ អត្រាអក្ខរកម្មជនពេញវ័យ*

នៅកម្ពុជា អត្រាអក្ខរកម្មជនពេញវ័យមានភាពប្រសើរឡើងសម្រាប់បុរស និងស្ត្រីចាប់តាំងពីឆ្នាំ ២០០៨ ដល់ឆ្នាំ ២០១៧ ប៉ុន្តែគម្លាតអក្ខរកម្មនៅតែមានរវាងភេទ ទីតាំងភូមិសាស្ត្រ និងតំបន់។ ក្រាហ្វិកទី១ បង្ហាញថាអត្រាអក្ខរកម្មរបស់ស្ត្រីនៅតែទាបជាងបុរសចំនួន ១៦,៩ភាគរយ នៅឆ្នាំ ២០០៨ និង ៩,២ ភាគរយ នៅឆ្នាំ ២០១៧ ហើយបើយោងតាមក្រាហ្វិកទី២ អត្រាអក្ខរកម្មរបស់ស្ត្រីគឺទាបជាងបុរសនៅគ្រប់ទីតាំងភូមិសាស្ត្រនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ២០១៧[5]។

*ក្រាហ្វិកទី១៖ អត្រាអក្ខរកម្មជនពេញវ័យ តាមភេទនៅកម្ពុជា ២០០៨-២០១៧ (%)*




ប្រភព៖ ការស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ ២០០៨-២០១៧

*ក្រាហ្វិកទី២: អត្រាអក្ខរកម្មជនពេញវ័យតាមភេទ និងទីតាំងភូមិសាស្ត្រនៅកម្ពុជា២០១៧ (%)*




ប្រភព៖ ការស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ ២០០៨-២០១៧

ទោះបីជាគម្លាតអក្ខរកម្មបានថយចុះ អត្រាអក្ខរកម្មជនពេញវ័យរបស់ស្ត្រីនៅកម្ពុជានៅទាបជាងបណ្តាប្រទេសមួយចំនួនក្នុងតំបន់ដូចជាឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបុរី និងវៀតណាមពីឆ្នាំ ២០០៨ ដល់ ២០១៧ (ក្រាហ្វិកទី៣) [6]។

*ក្រាហ្វិកទី៣៖ អត្រាអក្ខរកម្មជនពេញវ័យរបស់ស្ត្រីតាមប្រទេស ២០០៨-២០១៧ (%)*




ប្រភព៖ អគ្គលេខាធិការដ្ឋានអាស៊ានឆ្នាំ ២០១៨ និង ការស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ ២០០៨-២០១៧

*ក្រាហ្វិកទី៤៖ ផលធៀបចុះឈ្មោះចូលរៀនពិត តាមភេទនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សានៅកម្ពុជា ២០០៨-២០១៦ (%)*




ប្រភពអគ្គលេខាធិការដ្ឋានអាស៊ានឆ្នាំ ២០១៨

## ១.២ អត្រាចុះឈ្មោះចូលរៀន

ភាពស្មើគ្នាយេនឌ័រលើអត្រាចុះឈ្មោះចូលរៀនសម្រេចបានជាបណ្តើរៗនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅពីឆ្នាំ៨ដល់ឆ្នាំ ២០១៦។ ប៉ុន្តែផលធៀបនៃអត្រាចុះឈ្មោះចូលរៀនពិតរបស់ក្មេងប្រុសនិងក្មេងស្រីនៅមានកម្រិតទាបនៅឡើយនៅថ្នាក់មធ្យមសិក្សា បើធៀបនឹងបឋមសិក្សា (តិចជាង៤០ភាគរយ) (ក្រាហ្វិកទី៤) [6]។

បើធៀបជាមួយបណ្តាប្រទេសនៅអាស៊ាន ផលធៀបនៃអត្រាចុះឈ្មោះចូលរៀនពិតរបស់ក្មេងស្រីនៅថ្នាក់មធ្យមសិក្សារបស់កម្ពុជាមានកម្រិតទាបជាងគេ ធៀបជាមួយ ប្រទេសមីយ៉ាន់ម៉ា ម៉ាឡេស៊ី និងសិង្ហបុរី ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១៦ (ក្រាហ្វិកទី៥) [6]។

*ក្រាហ្វិកទី៥៖ ផលធៀបចុះឈ្មោះចូលរៀនពិតរបស់ក្មេងស្រីនៅថ្នាក់មធ្យមសិក្សាតាមបណ្តាប្រទេសនៅអាស៊ាន២០០៨- ២០១៦ (%)*




ប្រភព៖ អគ្គលេខាធិការដ្ឋានអាស៊ានឆ្នាំ ២០១៨

នៅថ្នាក់ឧត្តមសិក្សា និងមហាវិទ្យាល័យ អត្រាចុះឈ្មោះចូលរៀនរបស់ស្ត្រី ក៏មានវឌ្ឍនភាពល្អប្រសើរចាប់ពីឆ្នាំ ២០១១ ដល់ ២០១៦ ប៉ុន្តែគម្លាតយេនឌ័រនៅតែមានកម្រិតខ្ពស់ ជាពិសេសនៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត (ក្រាហ្វិកទី៦) [7, 8, 9, 10]។ អាស្រ័យហេតុនេះ វាជាការចាំបាច់ដែលកម្ពុជា ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅកម្រិតឧត្តមសិក្សា។

*ក្រាហ្វិកទី ៦៖ អត្រាចុះឈ្មោះចូលរៀនរបស់ស្ត្រីនិងបុរសនៅថ្នាក់ឧត្តមសិក្សា នៅកម្ពុជា ២០១១- ២០១៦ (%)*




ប្រភព៖ ក្រសួងអប់រំយុវជន និងកីឡា ២០១២-២០១៦

## ១.៣ អត្រាបោះបង់ការសិក្សា

អត្រាបោះបង់ការសិក្សាបានថយចុះ ជាលំដាប់ទាំងក្មេងប្រុស និងក្មេងស្រី នៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៧។ ប៉ុន្តែនៅថ្នាក់មធ្យមសិក្សាទុតិយភូមិ អត្រាបោះបង់ការសិក្សារបស់ក្មេងស្រី មានការប្រែប្រួលដោយ បានថយចុះជាលំដាប់ពី១៣,១ ភាគរយ នៅឆ្នាំ២០០៧-២០០៨ ទៅដល់៩,៨ភាគរយ នៅឆ្នាំ២០១១-២០១២ ប៉ុន្តែបានកើនឡើង ដល់២៥,៤ភាគរយនៅឆ្នាំ២០១៣-២០១៤ និងថយចុះវិញដល់១៧ភាគរយនៅឆ្នាំ២០១៦-២០១៧ [11, 12, 13, 14, 15, 16, 17] (ក្រាហ្វិកទី៧)។ ចំនុចនេះបង្ហាញថាក្មេងស្រីនៅកម្ពុជានៅតែជួបបញ្ហាប្រឈមក្នុងការបន្តការសិក្សានៅកម្រិតខ្ពស់។ ទោះបីអត្រាបោះបង់ការសិក្សារបស់ក្មេងស្រីទាបជាងក្មេងប្រុសក្តី អត្រាបោះបង់ការសិក្សាខ្ពស់របស់ក្មេងស្រីនៅថ្នាក់មធ្យមសិក្សាទុតិយភូមិអាចបង្កជាហានិភ័យដល់កម្ពុជាក្នុងការមានចំនួនក្មេងស្រីច្រើនជាងបណ្តាប្រទេសនានានៅអាស៊ានដែលមានកម្រិតអប់រំទាប។

*ក្រាហ្វិកទី៧៖ អត្រាបោះបង់ការសិក្សាថ្នាក់ជាតិ តាមភេទនៅថ្នាក់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ២០០៧-២០១៧ នៅកម្ពុជា (%)*




ប្រភព៖សៀវភៅស្ថិតិ និងសូចនាករអប់រំ ឆ្នាំ ២០០៧-២០១៧ ក្រសួងអប់រំ យុវជន និងកីឡា

ផ្អែកតាមរូបភាព៨ អត្រាបោះបង់ការសិក្សារបស់ក្មេងស្រីនៅថ្នាក់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិនៅកម្ពុជាមានការប្រែប្រួលទៅតាម ទីតាំងភូមិសាស្ត្រ។ អត្រាបោះបង់ការសិក្សារបស់ក្មេងស្រីនៅជនបទហាក់ដូចជាមានកម្រិតខ្ពស់ជាងអត្រាបោះបង់ការសិក្សារបស់ក្មេងស្រីនៅទីប្រជុំជនពីឆ្នាំ២០១១ដល់ឆ្នាំ២០១៧[14, 15, 16, 17]។ ចំនុចនេះមានន័យថា កម្ពុជាគួរមានអន្តរាគមន៍បន្ថែមទៀតក្នុងការដោះស្រាយបញ្ហាបង់ការសិក្សារបស់ក្មេងស្រីនៅជនបទ។

*ក្រាហ្វិកទី៨៖ អត្រាបោះបង់ការសិក្សាថ្នាក់ជាតិរបស់ក្មេងស្រីតាមទីតាំងភូមិសាស្ត្រនៅថ្នាក់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ២០១១-២០១៧នៅកម្ពុជា (%)*




ប្រភព៖ សៀវភៅស្ថិតិ និងសូចនាករអប់រំ ឆ្នាំ ២០១១-២០១៧ ក្រសួងអប់រំ យុវជន និងកីឡា

## *១.៤ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ*(TVET)

នៅកម្ពុជា អត្រាចុះឈ្មោះចូលរៀនរបស់បុរសនៅក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមានកម្រិតខ្ពស់ជាងស្ត្រីស្ទើររៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១២ដល់ឆ្នាំ២០១៨ ប៉ុន្តែអត្រាបោះបង់ការសិក្សារបស់បុរសក៏មានកម្រិតខ្ពស់ជាងស្ត្រីផងដែរ (ក្រាហ្វិកទី៩) [18, 19, 20, 21, 22, 23]។ បន្ថែមពីនេះ គម្លាតយេនឌ័រពាក់ព័ន្ធនឹងការជ្រើសរើសមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យានៅតែមាននៅកម្ពុជា ឧទាហរណ៍នៅថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រ បុរសទំនងជាចុះឈ្មោះចូលរៀនមុខវិជ្ជាអគ្គិសនី វិស្វកម្ម យានយន្ត ព័ត៌មានវិទ្យា និងអេឡិចត្រូនិច ដោយឡែកស្ត្រីទំនងជាចុះឈ្មោះចូលរៀនមុខវិជ្ជាគណនេយ្យ និងហិរញ្ញវត្ថុ ភាសាអង់គ្លេស អគ្គិសនី និងព័ត៌មានវិទ្យានៅឆ្នាំ២០១៧-២០១៨ (ក្រាហ្វិកទី១០)។

*ក្រាហ្វិកទី៩៖ អត្រាចុះឈ្មោះចូលរៀន និងអត្រាបោះបង់ការសិក្សាថ្នាក់ជាតិរបស់បុរស និងស្ត្រីនៅកម្រិតអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២០១២-២០១៨ នៅកម្ពុជា (%)*




ប្រភព៖ ក្រសួងការងារ និងបណ្តុះបណ្តាលបច្ចេកទេស វិជាជីវៈ២០១៤-២០១៩

*ក្រាហ្វិកទី១០៖ អត្រាចុះឈ្មោះចូលរៀនរបស់ស្ត្រី និងបុរសតាមមុខជំនាញ នៅថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រនៅកម្រិតអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២០១៧-២០១៨ នៅកម្ពុជា*




ប្រភព៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៩

ការចុះឈ្មោះ(ស) ការស្ទង់មតិរបស់អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច(OECD) ជាមួយសិស្សដែលមានអាយុ១៥ឆ្នាំលើកម្មវិធីសម្រាប់វាយតម្លៃសិស្សអន្តរជាតិ (PISA) នៅឆ្នាំ២០១៥បង្ហាញថា ប្រទេសសិង្ហបុរីបានជាប់ចំណាត់ថ្នាក់លេខ១ក្នុងការដែលមានសិស្សមានចំណេះដឹងលើមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យាដោយទទួលបានពិន្ទុមធ្យមចំនួន៥៥៦ និង៥៦៤ ដែលធ្វើបានល្អជាងប្រទេសជប៉ុន អេសតូនៀ ហ្វាំងឡង់ និងកាណាដា រីឯប្រទេសវៀតណាមជាប់ចំណាត់ថ្នាក់លេខ៨សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ និងលេខ២០សម្រាប់មុខវិជ្ជាគណិតវិទ្យា បន្ទាប់មកគឺប្រទេសថៃ និងឥណ្ឌូនេស៊ី។ ប្រទេសកម្ពុជាពុំបានចូលរួមនៅក្នុងការស្ទង់មតិនេះទេ ដោយសារតែប្រទេសនេះទើបតែចាប់ផ្តើមក្នុងការអនុវត្តគោលនយោបាយសាលារៀនជំនាន់ថ្មីនៅឆ្នាំ២០១៦ ដែលផ្តោតទៅលើវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) [24]។ ទោះជាយ៉ាងណាក៏ដោយ កម្ពុជានៅតែអាចរៀនសូត្រពីបណ្តាប្រទេសនៅអាស៊ានដើម្បីលើកកម្ពស់ចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យាដើម្បីត្រៀមចូលរួមនៅក្នុងបដិវត្តន៍ឧស្សាហកម្មទី៤។

## ២. បញ្ហាប្រឈម

ទោះបីជាអត្រាចុះឈ្មោះចូលរៀនកម្រិតបឋមសិក្សា និងមធ្យមសិក្សាមានវឌ្ឍនភាពល្អប្រសើរក្តី ក៏កម្ពុជានៅតែជួបបញ្ហាសមភាពយេនឌ័រពាក់ព័ន្ធនឹងការអប់រំតាមទីតាំងភូមិសាស្ត្រ អត្រាអក្ខរកម្មជនពេញវ័យ ការអប់រំកម្រិតឧត្តមសិក្សា និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ បើធៀបជាមួយបណ្តាប្រទេសនៅអាស៊ានការចូលរួមរបស់ស្ត្រីក្នុងវិស័យអប់រំរបស់កម្ពុជានៅទាបជាងបណ្តាប្រទេសមួយចំនួនដូចជា វៀតណាម ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងសិង្ហបុរី នេះរួមបញ្ចូលទាំងសមត្ថភាពរបស់សិស្សពាក់ព័ន្ធ វិទ្យាសាស្ត្រ និងគណិតវិទ្យា។ កត្តាដែលរារាំងដល់ការសម្រេចបានសមភាពយេនឌ័រក្នុងវិស័យអប់រំនៅកម្ពុជាមានដូចខាងក្រោម៖

- **បទដ្ឋានសង្គម និងយេនឌ័រនៅតែជាកត្តារួមចំណែក៖** ស្ត្រីកម្ពុជានៅតែប្រឈមនឹងបទដ្ឋានសង្គម និងយេនឌ័រក្នុងការបន្តការសិក្សានៅកម្រិតខ្ពស់។ កត្តានេះមួយផ្នែកបណ្តាលមកពីអនក្ខរកម្ម និងកម្រិតអប់រំរបស់ឪពុកម្តាយនៅមានកម្រិតទាប ព្រមទាំង ការយល់ដឹងរបស់ពួកគេនៅមានកម្រិតពាក់ព័ន្ធនឹងផលប្រយោជន៍យូរអង្វែងនៃការអប់រំសម្រាប់ក្មេងស្រី ជាពិសេសនៅក្នុងគ្រួសារជនជាតិភាគតិច[25]។
- **ភាពក្រីក្រ៖** គ្រួសារក្រីក្រជាច្រើននៅតាមទីជនបទមិនអាចបញ្ជូនកូនរបស់គេទៅសាលារៀន ហើយមូលហេតុនោះគឺដោយសារភាពក្រីក្រនៅក្នុងគ្រួសារ[26] និងតម្លៃឱកាសខ្ពស់សម្រាប់ការអប់រំ[25]។ គ្រួសារជាច្រើនត្រូវធ្វើចំណាកស្រុកជាមួយកូនៗរបស់គេទៅកាន់ប្រទេសផ្សេងៗដើម្បីចិញ្ចឹមជីវិត ធ្វើឲ្យកូនៗរបស់គេមានឱកាសតិចតួចក្នុងការទទួលបានការអប់រំ។
- **ការចូលរួមរបស់ឪពុកម្តាយ និងសហគមន៍នៅក្នុងការអប់រំកូននៅមានកម្រិតនៅឡើយ៖** ការចូលរួមរបស់ឪពុកម្តាយនៅក្នុងការអប់រំកូននៅផ្ទះ និងសាលារៀនគឺមានសារៈសំខាន់ ប៉ុន្តែនៅកម្ពុជា ការចូលរួមរបស់ឪពុកម្តាយ និងសហគមន៍នៅមានភាពទន់ខ្សោយ និងមិនទៀងទាត់[25]។ ការចូលរួមរបស់ឪពុកម្តាយមិនត្រឹមតែសំដៅលើវត្តមាននៃការចូលរួមប៉ុណ្ណោះទេ ប៉ុន្តែក៏សំដៅទៅលើ ជំនឿរបស់ឪពុកម្តាយដែលឲ្យតម្លៃទៅលើសារៈសំខាន់នៃការសម្រេចបានលើការសិក្សារបស់កូនផងដែរ[27]។
- **កិច្ចការពារកុមារនៅតាមសាលារៀន និងសុវត្ថិភាពសម្រាប់ក្មេងស្រីនៅមិនទាន់សម្រេចបានពេញលេញនៅឡើយ៖** ទោះបីជាគោលនយោបាយសាលាកុមារមេត្រីត្រូវបានអនុម័តតាំងពីឆ្នាំ២០០៧ក្តី ការអនុវត្តគោលនយោបាយនេះនៅមិនទាន់សម្រេចបានពេញលេញនោះទេ។ បញ្ហានៃការបំពាក់សម្ភារៈសម្រាប់ទឹកស្អាត បង្គន់អនាម័យ និងលាងដៃនៅតែជាបញ្ហានៅតាមសាលារៀនជាច្រើន[28]។ ការសិក្សាស្ទង់មតិមូលដ្ឋានមួយរបស់វិទ្យាស្ថានអន្តរជាតិសម្រាប់ការស្រាវជ្រាវលើស្ត្រី និងអង្គការផែនការអន្តរជាតិ ( Plan International ) នៅឆ្នាំ២០១៤ បានបង្ហាញថា ៤៧ ភាគរយ នៃសិស្ស បានវាយតម្លៃសាលារៀនរបស់គេថាមិនសូវមានសុវត្ថិភាពឬ មិនមានសុវត្ថិភាពទាំងស្រុង និង៧៣ភាគរយ ឆ្លើយថាធ្លាប់បានទទួលរងយ៉ាងហោចណាស់ទម្រង់មួយនៃអំពើហិង្សានៅក្នុងសាលារៀន[29]។
- **ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅមិនទាន់គេឲ្យតម្លៃ និងត្រូវបានចាត់ទុកថាជាជំនាញដែលមិនសមស្របសម្រាប់ស្ត្រី៖** ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅតែត្រូវបានចាត់ទុកជាជំនាញអាទិភាពទីពីរសម្រាប់សិស្សស្រីបន្ទាប់ពីបញ្ចប់មធ្យមសិក្សាទុតិយភូមិ។ ម្យ៉ាងទៀត បទដ្ឋានវប្បធម៌ និងសង្គមក៏នៅតែកំណត់ប្រភេទមុខរបរដែលសមស្របសម្រាប់ស្ត្រី ហើយជាញឹកញាប់ការងារគ្រឿងយន្តនិងសំណង់នៅតែត្រូវបានចាត់ទុកថាជាជំនាញមិនសមស្របសម្រាប់ស្ត្រី [30]។
- **ស្ត្រីខ្វះព័ត៌មាន ធនធាននិងការអប់រំពាក់ព័ន្ធនឹងផលប្រយោជន៍នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ៖** ស្ត្រីមិនបានយល់ដឹងគ្រប់គ្រាន់អំពីឱកាសការងារ និងជំនួញដែលអាចទទួលបានពីកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ពួកគេក៏ខ្វះធនធានគាំទ្រដូចជាកន្លែងស្នាក់នៅ និងការចំណាយប្រចាំថ្ងៃក្នុងការស្នាក់នៅនិងរៀនសូត្រនៅតាមស្ថាប័នអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ស្ត្រីខ្លះទៀតក៏មិនទទួលបានការលើកទឹកចិត្តគ្រប់គ្រាន់អំពីការធ្វើការងារនៅក្នុងជំនាញ

បច្ចេកទេស ឧស្សាហកម្ម និងជំនួញ។ មួយផ្នែកដោយសារតែស្ត្រីទាំងនោះនិងគ្រួសាររបស់គេមិនទទួលបានការអប់រំឲ្យបានគ្រប់គ្រាន់ ដើម្បីស្វែងយល់ពីការងារ និងការធ្វើជំនួញដែលមិនឋិតជាជំនាញប្រពៃណីរបស់គេ[30]។

- **ការអនុវត្តគោលនយោបាយ និងសមត្ថភាពស្ថាប័នសម្រាប់ការបញ្ជ្រៀបយេនឌ័រនៅមានភាពទន់ខ្សោយនៅឡើយ៖** មានគោលនយោបាយនិងផែនការជាច្រើនត្រូវបានរៀបចំឡើងដើម្បីគាំទ្រក្មេងស្រីឲ្យទៅសាលារៀន ប៉ុន្តែការអនុវត្តគោលនយោបាយនិងផែនការទាំងនោះនៅមានចំនុចខ្វះខាតនៅឡើយ។ ជាក់ស្តែង បើទោះបីការអប់រំចំណេះទូទៅមិនតម្រូវឲ្យចំណាយថវិកាក្តី កុមារនៅតែត្រូវទទួលរងការចំណាយក្រៅផ្លូវការលើការអប់រំរបស់គេ។ សមត្ថភាពរបស់ស្ថាប័ន និងធនធានមនុស្សដើម្បីគាំទ្រ និងបញ្ជ្រៀបយេនឌ័រនៅក្នុងវិស័យអប់រំនៅមានកម្រិតនៅឡើយនៅឯថ្នាក់ក្រោមជាតិ[25]។

## ៣. ក្របខណ្ឌច្បាប់ និងគោលនយោបាយជាតិ

ការបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងវិស័យអប់រំត្រូវបានគាំទ្រដោយច្បាប់ និងគោយនយោបាយជាច្រើននៅកម្ពុជាចាប់តាំងពីឆ្នាំ២០០៧។

- មាត្រា៣១នៃច្បាប់អប់រំនៅកម្ពុជាអនុម័តនៅឆ្នាំ២០០៧ បានទទួលស្គាល់ថាបុរស និងស្ត្រីមានសិទ្ធិក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព និងមិនគិតថ្លៃសម្រាប់រយៈពេល៩ឆ្នាំនៅសាលារដ្ឋ[31]។
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រដ្ឋាភិបាលបានបង្ហាញអំពីកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលនៅក្នុងការពង្រឹងសមភាពយេនឌ័រ ដែលរួមមានការកាត់បន្ថយគម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ[32]។
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣)មានទិសដៅបង្កើនចំនួនស្ត្រីចុះឈ្មោះចូលរៀននៅថ្នាក់ឧត្តមសិក្សា ជាពិសេសពាក់ព័ន្ធនឹងជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម ការច្នៃប្រឌិត និងគណិតវិទ្យា[33]។
- ផែនការយុទ្ធសាស្ត្រ នារីរតនៈទី៤របស់ក្រសួងកិច្ចការនារី មានគោលបំណងលើកកម្ពស់ស្ត្រី និងក្មេងស្រីក្នុងការទទួលបានការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈការជម្រុញការចូលរួម ការយល់ដឹង និងលក្ខខណ្ឌគាំទ្រដល់ស្ត្រី[4]។
- នៅក្នុងវិស័យអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០១៤-២០១៨) និងគោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា ២០៣០ របស់ក្រសួងអប់រំ យុវជន និងកីឡា មានគោលបំណងបន្តដោះស្រាយបញ្ហាយេនឌ័រនៅក្នុងវិស័យអប់រំនៅគ្រប់កម្រិតតាមរយៈការរៀបចំកម្មវិធីអាហារូបករណ៍ថ្នាក់ជាតិ និងការអភិវឌ្ឍសមត្ថភាពសម្រាប់ស្ត្រី[34, 35]។
- ផែនការសកម្មភាពនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៥របស់ក្រសួងអប់រំ យុវជន និងកីឡា មានគោលបំណងធានាឲ្យកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបញ្ជ្រៀបនូវការអប់រំបែបបរិយាប័ន្ន និងយេនឌ័រ[36]។

- គោលនយោបាយសាលាកុមារមេត្រីដែលអនុម័តនៅឆ្នាំ២០០៧មានគោលបំណងធានាឲ្យមានការអប់រំបែបបរិយាប័ន្ន សម្រាប់ក្មេងស្រី និងក្មេងប្រុស ការសិក្សាប្រកបដោយប្រសិទ្ធិភាព សុវត្ថិភាព និងកិច្ចការពារកុមារ និងការឆ្លើយតបនឹងយេនឌ័រ[37]។
- គោលនយោបាយយេនឌ័រ និងផែនការសកម្មភាព ២០១៧-២០២៦របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានគោលបំណងធានាឲ្យបុរស និងស្ត្រីមានឱកាសស្មើគ្នាក្នុងការសិក្សា និងទទួលផលប្រយោជន៍ពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមរយៈការបង្កើនចំណេះដឹង និងការផ្លាស់ប្តូរផ្នត់គំនិតអំពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការផ្តល់ធនធានហិរញ្ញវត្ថុ ការស្នាក់នៅ ឧបករណ៍ និងកម្មវិធីអភិវឌ្ឍការងារ និងការណែនាំដល់ស្ត្រី[30]។

## II. ស្ត្រី និងការទទួលបានសេវាលើកកម្ពស់សុខភាពមាតា និងទារក

### ១.បរិបទ

ការធានាឲ្យបាននូវការទទួលបានសេវាសុខភាពសម្រាប់ស្ត្រី ជាពិសេសសេវាលើកកម្ពស់សុខភាពមាតានិងទារក ត្រូវបានដាក់បញ្ចូលទៅក្នុងសុច្ចនាករទី៣នៃគោលដៅអភិវឌ្ឍប្រកបដោយនិរន្តរភាព (SDG3)។ ៩នាក់ក្នុងចំណោមស្ត្រីកម្ពុជា១០នាក់បានទទួលសេវាថែទាំគភ៌មុនសម្រាល(Antenatal Healthcare-ANC) ។ ក៏ប៉ុន្តែសម្រាប់ស្ត្រីក្រីក្រ និងស្ត្រីដែលមានកំរិតអប់រំតិចតួចមួយចំនួន ការទទួលបានសេវា ANC គឺនៅមានកម្រិត។ នេះគឺឆ្លុះបញ្ចាំងពីទិដ្ឋភាពខ្លះនៃវិសមភាពក្នុងការទទួលបានសេវាសុខភាពក្នុងចំណោមស្ត្រី។ រាជរដ្ឋាភិបាលដោយមានកិច្ចសហការពីដៃគូរពាក់ព័ន្ធ បាននឹងកំពុងអនុវត្តគោលនយោបាយ និងកម្មវិធីនានាពាក់ព័ន្ធនឹងការលើកកម្ពស់សុខភាពមាតា និងទារក។ ជំពូកទីពីរនៃអត្ថបទស្រាវជ្រាវនេះផ្តល់នូវសេចក្តីសង្ខេបពាក់ព័ន្ធ និងកាលានុវត្តភាពពាក់ព័ន្ធនឹងសេវាសុខភាពមាតា និងទារកដោយផ្តោតលើ (១)ការពង្រីកសេវាសុខភាព (២)ការទទួលបានសេវាសុខភាព និង(៣) ក្របខ័ណ្ឌគោលនយោបាយ។ ជំពូកនេះ ក៏បានធ្វើការសិក្សាប្រៀបស្ថានភាពសេវាសុខភាពមាតា និងទារកក្នុងប្រទេសកម្ពុជាដោយធៀបជាមួយ និងប្រទេសមួយចំនួនក្នុងតំបន់ និងប្រទេសចំណូលមធ្យមកម្រិតទាបផងដែរ។ ការសិក្សានេះពឹងផ្អែកទាំងស្រុងលើទិន្នន័យដែលមានស្រាប់។

### ២. បម្រែបម្រួល និងបច្ចុប្បន្នភាពរបស់ស្ថានភាពសុខភាពមាតា និងទារក

អត្រាមរណភាពមាតា (Maternal Mortality Ratio-MMR) ក្នុងប្រទេសកម្ពុជាមានការធ្លាក់ចុះគួរឲ្យកត់សំគាល់។ យោងតាមស្ថិតិធនាគារពិភពលោក MMR ក្នុងប្រទេសកម្ពុជាគឺ ១.០២០ ក្នុងទារកកើតរស់ ១០០.០០០ នាក់ក្នុងឆ្នាំ ១៩៩០ ដែលនេះគឺជាតួលេខខ្ពស់ជាងគេក្នុងតំបន់បើធ្វើការប្រៀបធៀបជាមួយឡាវ (៩០៥ ក្នុងទារកកើតរស់១០០.០០០នាក់) និងមីយ៉ាន់ម៉ា (៤៥៣ ក្នុងទារកកើតរស់១០០.០០០នាក់) (ក្រាហ្វិកទី ១១)។ អត្រា MMRខ្ពស់នេះ ច្រើនតែទាក់ទងនឹងការហូរឈាម សម្ពាធឈាមខ្ពស់ និងការរំលូតកូនគ្មានសុវត្ថិភាពដែលបណ្តាលមកពីកង្វះអាហារូបត្ថម្ភ និងកង្វះអនាម័យ[38]។ ប្រទេសថៃ និងវៀតណាមមាន MMR ក្នុងកម្រិតទាប ដែលនេះសរបញ្ជាក់ពីភាពជឿនលឿនជាងនៃវិស័យសុខភាពក្នុងប្រទេសទាំងពីរ។ MMR ត្រូវបានកាត់បន្ថយជាលំដាប់នៅក្នុងពីទសវត្សចុងក្រោយ ដោយធ្លាក់នៅពីក្រោមប្រទេសឡាវនៅឆ្នាំ ១៩៩៨ និងប្រទេសមីយ៉ាន់ម៉ានៅឆ្នាំ ២០១០។ ត្រឹមឆ្នាំ ២០១៥ MMR ក្នុងប្រទេសកម្ពុជាស្ថិតនៅត្រឹម១៦១ក្នុងទារកកើត

រស់១០០០០០នាក់ ដែលតួលេខ នេះស្ថិតនៅប្រសើរជាងតួលេខមធ្យមរបស់ប្រទេសចំណូលមធ្យមកំរិតទាបទៅទៀត។

*ក្រាហ្វិកទី១១៖ បម្រែបម្រួលនៃអត្រាមរណភាពមាតាក្នុងទារកកើតរស់១០០ ០០០នាក់ក្នុងប្រទេសអាស៊ានមួយចំនួនចាប់តាំងពីឆ្នាំ ១៩៩០*




ប្រភព ៖ ទិន្នន័យធនាគារពិភពលោក ២០១៨

ការធ្លាក់ចុះនៃ MMR ត្រូវបានគេមើលឃើញថាមានជាប់ទាក់ទងទៅនឹង (១)ការរីកចំរើនជារួមរបស់វិស័យសុខាភិបាលជាតិមានដូចជា ការពង្រីកសេវាសុខភាព ការផ្តល់នូវសេវាសុខភាព និង(២)ការប្រសើរឡើងនូវជីវភាពរស់នៅរបស់គ្រួសារ[39, 40, 41]។ ក្រសួងសុខាភិបាលបានប្រមើលថា MMR និងបន្តធ្លាក់ចុះទៅដល់១៣០ក្នុងទារកកើតរស់១០០.០០០នាក់ក្នុងឆ្នាំ ២០២០[41]។ បញ្ហាប្រឈមពីរដែលរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ដោះស្រាយគឺ (១)ការកាត់បន្ថយវិសមភាពក្នុងការទទួលបានសេវាសុខភាពរវាងស្ត្រីមកពីគ្រួសារក្រីក្រ និងស្ត្រីមកពីគ្រួសារមិនក្រីក្រ រវាងស្ត្រីដែលទទួលបានការអប់រំតិចតួច និងស្ត្រីដែលទទួលបានការអប់រំខ្ពស់ (២) និងការពង្រីកវិសាលភាពគ្របដណ្តប់របស់សេវាសុខភាពឲ្យបានទៅដល់ស្ត្រីក្រីក្រនៅតាមតំបន់ដាច់ស្រយាលមួយចំនួន [42, 43, 44, 45]។

### ៣.ការពង្រីកសេវាសុខភាពមាតា និងទារក

រដ្ឋាភិបាលបានប្រឹងប្រែងយ៉ាងខ្លាំងក្នុងការបង្កើន និងពង្រីកសេវាសុខភាពមាតា និងទារក តាមរយៈការបង្កើនថវិការជាតិសម្រាប់វិស័យសុខាភិបាល បង្កើនចំនួនមន្ទីរពេទ្យនិងមណ្ឌលសុខភាព ការកសាងផ្លូវនៅតំបន់ជនបទ និងការពង្រីកវិសាលភាពសេវាសុខភាពសម្រាប់ជនក្រីក្រ។ ក្នុងចន្លោះឆ្នាំ ២០០៨ ទៅ ២០១៨ ចំនួនមន្ទីរពេទ្យរដ្ឋ និងមន្ទីរពេទ្យបង្អែកស្រុកបានកើនឡើង២០ភាគរយពី ១១៦១ ទៅ ១៤៥៧ [41]។ ចំណាយរដ្ឋលើវិស័យសុខាភិបាលក៏បានកើនឡើងពី ៦,៣៩ ភាគរយ ក្នុងឆ្នាំ ២០១៥ ទៅដល់ ៨,៥ ភាគរយក្នុងឆ្នាំ ២០១៩ [41]។ សេវាសុខភាពសម្រាប់ស្ត្រីក្រីក្រមានដូចជា គម្រោងប្រាក់ឧបត្ថម្ភលើកទឹកចិត្តធ្មប កម្មវិធីមូលនិធិសមធម៌ ការបង់ថ្លៃជួស និងសេវាទ្រទ្រង់ហិរញ្ញវត្ថុសម្រាប់សុខភាពផ្សេងៗទៀតត្រូវបានដាក់ឲ្យប្រតិបត្តិ និង

កំពុងពង្រីកវិសាលភាព។ រដ្ឋាភិបាលកំពុងបន្តពង្រីកវិសាលភាពគ្របដណ្តប់របស់សេវាសុខភាព និងពង្រឹងគុណភាពរបស់សេវាទាំងនោះ ដើម្បីឆ្លើយតបទៅនឹងកំណើនតំរូវការសេវាសុខភាពពីសំណាក់ប្រជាជន[33]។

ការបង្កើនចំនួនមន្ទីរពេទ្យនិងមណ្ឌលសុខភាពគឺជាការចាំបាច់ដើម្បីឆ្លើយតបទៅនឹងកំណើនឥតឈប់ឈរនូវតម្រូវការ សេវាថែទាំគភ៌មុនសម្រាល និងសេវាសម្រាលដោយបុគ្គលិកសុខាភិបាល[46]។ ការផ្តល់និងការដាក់ឲ្យប្រើប្រាស់សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងថែទាំទារកកម្រិតពេញលេញ ហើយសេវាកម្រិតមូលដ្ឋាន (BEmONC)[i] នៅតាមមន្ទីរពេទ្យបង្អែកស្រុកបានចូលរួមចំណែកលើកកម្ពស់ការប្រើប្រាស់ ANC និងសេវាពិនិត្យក្រោយសម្រាល (Postnatal Care-PNC) ក្នុងចំណោមស្រ្តីមានផ្ទៃពោះ និងស្រ្តីដែលទើបឆ្លងទន្លេរួច។ មធ្យោបាយផ្សេងៗដើម្បីពង្រឹងការតាមដានមរណៈភាពមាតា និងទារកត្រូវបានដាក់ឲ្យប្រើប្រាស់[46]។ អាស្រ័យទៅដោយការរីកចំរើនទាំងនេះ ភាគរយស្ត្រីមានផ្ទៃពោះដែលទទួលបានសេវា ANC បានកើនពី ៣៧,៧ ភាគរយក្នុងឆ្នាំ ២០០៥ រហូតដល់ ៩៥,៣ភាគរយ ក្នុងឆ្នាំ ២០១៤ ដែលតួរលេខនេះប្រហាក់ប្រហែលនឹងរបស់ប្រទេសវៀតណាម និងតិចជាងថៃតែ៣ភាគរយប៉ុណ្ណោះ។ ប្រទេសក្នុងតំបន់ពីរទៀតគឺឡាវ និងមីយ៉ាន់ម៉ាក៏បានបង្ហាញនូវកាលានុវត្តភាពប្រសើរក្នុងការផ្តល់សេវា ANC ដែរ ដោយភាគរយស្ត្រីមានផ្ទៃពោះដែលទទួលបានសេវានេះគឺនៅក្នុងកម្រិតប្រមាណ ៨០ ភាគរយ(តារាងទី១)។

*តារាង ១៖ ភាគរយស្ត្រីមានផ្ទៃពោះទទួលបានសេវាថែទាំគភ៌មុនសម្រាល (ANC)*

| **ប្រទេស** | **ឆ្នាំ** | | |
|---|---|---|---|
| | **២០០០** | **២០១០** | **២០១៤** |
| កម្ពុជា | ៣៧,៧ | ៨៩,១ | ៩៥,៣ |
| ប្រទេសចំណូលមធ្យមកំរិតទាប | ៦៤,០ | n/a | ៨២,២ |
| ឡាវ | ២៦,៥ | ៧១ | ៧៨,៤(២០១៧) |
| មីយ៉ាន់ម៉ា | ៧៥,៦(២០០១) | ៨៣,១ | ៨០,៧(២០១៦) |
| ថៃ | ៩១,៨ | ៩៩,១(២០០៩) | ៩៨,១(២០១៦) |
| វៀតណាម | ៦៨,៣ | ៩៣,៧(២០១១) | ៩៥,៨ |

ប្រភព ៖ ទិន្នន័យធនាគារពិភពលោក ២០១៨ និងក្រសួងសុខាភិបាលឆ្នាំ២០១៩

អត្រានៃការសម្រាលដោយបុគ្គលិកសុខាភិបាលនៅក្នុងប្រទេសកម្ពុជាបានកើនឡើង៣ដងពី ៣០ ភាគរយ ក្នុងឆ្នាំ២០០០ដល់ ៨៩ ភាគរយ ក្នុងឆ្នាំ២០១៩(តារាងទី២)។ ការកើនឡើងនេះគឺស្របគ្នាជាមួយគ្នានឹងការកើនឡើងនូវវត្តមានរបស់សេវាសុខភាព។ អត្រានៃការសម្រាលដោយបុគ្គលិកសុខាភិបាលនៅក្នុងប្រទេសកម្ពុជាគឺច្រើនជាងអត្រាជាមធ្យមរបស់ប្រទេសចំណូលមធ្យមកម្រិតទាបទៅទៀត។ អត្រានៃការសម្រាលដោយបុគ្គលិកសុខាភិបាលគឺ ៦៤,៤ ភាគរយ សម្រាប់ប្រទេសឡាវ និង ៦០,២ ភាគរយ សម្រាប់មីយ៉ាន់ម៉ា។

[i] BEmONC សំដៅលើសេវាសង្គ្រោះបន្ទាន់សម្រាប់មាតា និងទារកដែលផ្តល់ដោយបុគ្គលិកពេទ្យជំនាញដើម្បីមរណភាពមាតា និងទារក

*តារាង ២៖អត្រានៃការសម្រាលដោយបុគ្គលិកសុខាភិបាល*

| ប្រទេស | ឆ្នាំ | | |
|---|---|---|---|
| | ២០០០ | ២០០៦ | ២០១៤ |
| កម្ពុជា | ៣១,៨ | 43.8 (2005) | ៨៩ (២០១៩) |
| ប្រទេសចំណូលមធ្យមកំរិតទាប | ៤៥ | n/a | ៧៤,៤ |
| ឡាវ | ១៦,៧ | ១៨,៩ | ៦៤,៤(២០១៧) |
| មីយ៉ាន់ម៉ា | ៥៧ (២០០១) | ៦៣,៩ (២០០៧) | ៦០,២ (២០១៦) |
| ថៃ | ៩៩,៣ | ៩៦,៩ | ៩៩,១ (២០១៦) |
| វៀតណាម | ៥៨,៨ | ៨៣,៨ | ៩៣,៨ |

ប្រភព ៖ ទិន្នន័យធនាគារពិភពលោក ២០១៨ និងក្រសួងសុខាភិបាលឆ្នាំ២០១៩

## ៤. ការទទួលបាន និងការប្រើប្រាស់សេវាលើកកម្ពស់សុខភាពមាតា និងទារក

សេវាលើកកម្ពស់សុខភាពមាតា និងទារកត្រូវបានដាក់ពង្រាយសម្រាប់ប្រើប្រាស់ស្ទើរទូទាំងប្រទេស។ ការកើនឡើងយ៉ាងឆាប់រហ័សនៃអត្រាប្រើប្រាស់សេវា ANC អត្រានៃការសម្រាលដោយបុគ្គលិកសុខាភិបាល និងការប្រើប្រាស់សេវាPNC ជាសក្ខីកម្មបញ្ជាក់ពីការរីកចំរើននៅក្នុងវិស័យសុខាភិបាល ការប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធជនបទ ក៏ដូចជាលទ្ធភាពរបស់គ្រួសារក្នុងការលៃលកសេវាលើកកម្ពស់សុខភាពមាតា និងទារក។ ទន្ទឹមនឹងការសម្រេចទាំងនេះ ទិន្ន័យបានបង្ហាញនូវវិសមភាពក្នុងការទទួលបានសេវាសុខភាពរវាងស្ត្រីនៅតំបន់ជនបទ និងស្ត្រីនៅទីក្រុង នេះសរបញ្ជាក់ឲ្យឃើញថាស្ត្រីនៅតំបន់ជនបទប្រឈមនឹងហានិភ័យសុខភាពខ្ពស់ជាងស្ត្រីនៅទីក្រុងកំឡុងពេលមានផ្ទៃពោះ និងពេលឆ្លងទន្លេ ។ បន្ថែមពីលើនេះ ការប្រើប្រាស់សេវាសុខភាពមាតានិងទារកមានទំនាក់ទំនងផ្ទាល់ជាមួយនឹងកម្រិតអប់រំរបស់ស្ត្រីផងដែរ។ ដូច្នេះការផ្តល់ការអប់រំដល់ស្ត្រីមានសារៈសំខាន់ណាស់ក្នុងការជំរុញឲ្យស្ត្រីប្រើប្រាស់សេវាសុខភាពនេះកាន់តែច្រើន[47]។

តារាងទី៣សង្ខេបទិន្នន័យពាក់ព័ន្ធនឹងការទទួលបានសេវាសុខភាពមាតា និងទារកក្នុងប្រទេសកម្ពុជា ពីឆ្នាំ ២០០០ និង ២០១៤។ អត្រាស្ត្រីមានផ្ទៃពោះដែលបានទទួលសេវាANCបានកើនឡើងជាលំដាប់ទាំងតំបន់ទីក្រុងនិងជនបទ។ ក្នុងឆ្នាំ ២០០០ មានស្ត្រីមានផ្ទៃពោះម្នាក់ក្នុងចំណោមបួននាក់ប៉ុណ្ណោះនៅតាមតំបន់ជនបទដែលបានទទួលសេវា ANC។ ការរីកចំរើននៃការទទួលបានសេវា ANC ក៏ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងអត្រាស្ត្រីមានផ្ទៃពោះដែលបានទទួលវ៉ាក់សាំងប្រឆាំងនឹងជំងឺតេតាណូសពីកម្មវិធីវ៉ាក់សាំងជាតិ[46]។

ស្ត្រីមានផ្ទៃពោះស្ទើរតែទាំងអស់ដែលរស់នៅតំបន់ទីប្រជុំជនបានសម្រាលកូននៅមន្ទីរពេទ្យរដ្ឋ។ អត្រាសម្រាលនៅមន្ទីរពេទ្យក្នុងចំណោមស្ត្រីនៅតំបន់ជនបទគឺ ៨១ ភាគរយ តួលេខនេះបានបង្ហាញថាគឺតិចជាង ១០ ភាគរយ បង្ហាញពីការថយចុះនៃអត្រា MMR ក្នុងរយៈពេលមួយ។ ការទទួលបានសេវា PNC ក៏មានការកើនឡើងគួរឲ្យកត់សម្គាល់។ នៅឆ្នាំ ២០០០ អត្រាស្ត្រីទទួលបានសេវា PNC គឺត្រឹមតែច ២០ ទៅ ៣០ភាគរយ ទាំងនៅតំបន់ជនបទ និងទីប្រជុំជន។ មកទល់នឹងឆ្នាំ ២០១៤ អត្រាស្ត្រីមានផ្ទៃពោះបានកើនឡើងដល់ទៅ ៩៨ភាគរយសម្រាប់ទីប្រជុំជន និង ៨៩,៩ ភាគរយនៅជនបទបានទទួលសេវា PNC។ អត្រាទទួលបានសេវាPNC នៅ

ប្រទេសមីយ៉ាន់ម៉ា គឺមានរហូតដល់ ៧១ ភាគរយ ក្នុងឆ្នាំ ២០១៥ ខណៈដែលប្រទេសឡាវមានតែ ៤១ ភាគរយ សម្រាប់ទារកទើបនឹងកើតដែលបានទទួលបានសេវា PNC ក្នុងរយៈពេលពីរថ្ងៃបន្ទាប់ពីការសម្រាល [48, 49]។ នៅប្រទេសថៃ ស្ទើរតែ ១០០ភាគរយ ទទួលបានសេវា PNC ដោយមានសមធម៌ខ្ពស់រវាងតំបន់ជនបទ និងទីប្រជុំជន[50]។

*តារាង ៣៖ការទទួលបានសេវាសុខភាពមាតានិងទារកតាមតំបន់ក្នុងប្រទេសកម្ពុជា*

| សុចនាករ | ២០០០ | | ២០១៤ | |
|---|---|---|---|---|
| | **ទីប្រជុំជន** | **ជនបទ** | **ទីប្រជុំជន** | **ជនបទ** |
| អត្រាទទួលបានសេវាថែទាំគភ៌មុនសម្រាលពីបុគ្គលិកសុខាភិបាល | ៦២,៣ | ៣៣,៨ | ៩៨,៦ | ៩៤,៨ |
| អត្រាទទួលបានវ៉ាក់សាំងបង្ការជំងឺតេតាណូសសម្រាប់មាតា និងទារក | ៤៥ | ២៧,៦ | ៩២,៩ | ៨៧,៨ |
| អត្រានៃការសម្រាលនៅ មូលដ្ឋានសុខភិបាល | ៣៦,៨ | ៦,៦ | ៩៦ | ៨១ |
| អត្រានៃការសម្រាលដោយបុគ្គលិកសុខាភិបាល | ៥៧,២ | ២៨ | ៩៧,៨ | ៨៧,៦ |
| អត្រាទទួលបានសេវាថែទាំមាតានិងទារកក្រោយសម្រាលពីរថ្ងៃ | ២៦,១ | ៣១,៨ | ៩៨,១ | ៨៩,៨ |

ប្រភព៖ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០០០ និង២០១៤

## ៥.លទ្ធភាពចំណាយសេវាសុខភាពមាតា និងទារក

លទ្ធភាពចំណាយសេវាសុខភាពមាតា និងទារកអាស្រ័យទៅលើកត្តាសង្គមសេដ្ឋកិច្ចមួយចំនួនដូចជា ថ្លៃសេវា ចំណូលគ្រួសារ កម្រិតអប់រំ មុខរបររបស់ស្ត្រី និងប្តី ព្រមទាំងកម្រិតជីវភាពគ្រួសារ [51]។ ភាពក្រីក្រ និងបញ្ហាហិរញ្ញវត្ថុជាកត្តាចម្បងរបស់ស្ត្រីក្នុងការទទួលបានសេវាសុខភាពមិនគ្រប់គ្រាន់។ ការប្រើប្រាស់ប្រាក់ចំណូលតិចតួចរបស់គ្រួសារសម្រាប់សេវាថែទាំសុខភាពអាចធ្វើឲ្យគ្រួសារធ្លាក់ខ្លួនជំពាក់បំណុលគេ ហើយគ្រួសារដែលមានសេដ្ឋកិច្ចសង្គមទាបអាចធ្លាក់ចូលក្នុងភាពក្រីក្រ[52, 53]។ ខ្វះការផ្តល់ភាពអង់អាចដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ ហើយនឹងការលំបាកក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុក្នុងគ្រួសារសម្រាប់ការថែទាំសុខភាពមាតា និងទារករបស់ពួកគេជាបុព្វហេតុធ្វើឲ្យស្ត្រីងាយប្រឈមទៅនឹងហានិភ័យសុខភាពនានាកំឡុងពរពោះ [54]។ ហើយក្នុងករណីខ្លះ ជំនឿបែបប្រពៃណីផ្សេងៗមានឥទ្ធិពលដល់សុខភាពបន្តពូជរបស់ស្ត្រី រួមទាំងអត្រាកំណើត ការប្រើប្រាស់ និងការទទួលបានវិធីសាស្ត្រពន្យារកំណើត និងការទទួលបានសេវាសុខភាពមាតា និងទារក។ កត្តាទាំងនេះនាំមកនូវផលអវិជ្ជមានដល់សុខភាពស្ត្រី[55]។

លទ្ធផលពីការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាបង្ហាញនូវវិសមភាពក្នុងការទទួលបានសេវាសុខភាពមាតា និងទារករវាងស្ត្រីដែលមកពីក្រុមគ្រួសារដែលមានកម្រិតជីវភាពផ្សេងគ្នា( តារាងទី៤ )។ អត្រាប្រើប្រាស់សេវា ANC ប្រែប្រួលក្នុងរវាងពី ៨៩ ទៅ ៩៩ ភាគរយ រវាងស្ត្រីមានជីវភាពទាបបំផុត និងខ្ពស់បំផុត មានន័យថា មាន

តែស្ត្រី ១០ ភាគរយ ប៉ុណ្ណោះដែលមកពីគ្រួសារក្រីក្រដែលពុំមានលទ្ធភាពចំណាយលើសេវាANC។ ស្ត្រីមានផ្ទៃពោះភាគច្រើនក្នុងប្រទេសបានទទួលវ៉ាក់សាំងបង្កាជំងឺតេតាណូស ដែលក្នុងនោះមានស្ត្រី ៨០ ភាគរយ មកពីគ្រួសារក្រីក្រអាចមានលទ្ធភាពទទួលបានសេវាកម្មនេះ បើប្រៀបធៀបនឹងស្ត្រី ៩៣ ភាគរយ មកពីគ្រួសារមិនក្រីក្រ។ នៅនិយាយដល់ភាពងាយស្រួលនៃការទទួលបានការសម្រាលកូន ទិន្នន័យបង្ហាញពីភាពខុសគ្នាយ៉ាងខ្លាំងពីលទ្ធភាពទទួលបានសេវារវាងស្ត្រីមកពីគ្រួសារគ្រួសារក្រីក្របំផុត និងស្ត្រីដែលមកពីគ្រួសារមិនក្រីក្រ។ អត្រាសម្រាលកូននៅមណ្ឌលសុខភាពមានភាពខុសគ្នាខ្លាំងរវាង ៦៨ ភាគរយ ទៅ៩៥ភាគរយបានទទួល ឬអាចចំណាយលើសេវា រវាងស្ត្រីដែលមកពីគ្រួសារក្រីក្រ និងស្ត្រីដែលមកពីគ្រួសារមិនក្រីក្រ។ ទន្ទឹមនឹងនេះអត្រាសម្រាលដោយធ្មបជំនាញ មាន ៩៥ ភាគរយ ក្នុងចំណោមស្ត្រីមកពីគ្រួសារមិនក្រីក្រ ដែលប្រហែលជា២៣ភាគរយខ្ពស់ជាងស្ត្រីមកពីគ្រួសារក្រីក្រ។ តម្លៃនៃសេវាសម្រាល គួបផ្សំនឹងចំងាយឆ្ងាយពីមណ្ឌលសុខភាព ជាមូលហេតុចម្បងដែលស្ត្រីក្រីក្រីទទួលបានសេវាលើកកម្ពស់សុខភាពមាតា និងទារកបានតិចតួច ជាពិសេសនៅតាមបណ្តាខេត្តដាច់ស្រយាលមួយចំនួន ដូចជា រតនៈគីរី និងមណ្ឌលគីរី [43, 56]។ វិសមភាពក្នុងការទទួលបានសេវាលើកកម្ពស់សុខភាពមាតា និងទារកក៏កើតមាននៅក្នុងចំណោមស្ត្រីមកពីក្រុមផ្សេងៗក្នុងប្រទេសតំបន់អាស៊ានផងដែរ ដូចជា ប្រទេសឡាវ មីយ៉ាន់ម៉ា និងប្រទេសវៀតណាម ដែលភាពក្រីក្រ និងចំងាយដើម្បីទទួលបានសេវា នៅតែជាបញ្ហាប្រឈមចម្បង[49, 57, 58, 59]។

*តារាង ៤៖ការទទួលបានសេវាសុខភាពមាតា និងទារកតាមប្រភេទកម្រិតជីវភាពក្នុងប្រទេសកម្ពុជា*

| សូចនាករ | ២០១៤ | | | | |
|---|---|---|---|---|---|
| | ទីទ័ល | ក្រីក្រ | មធ្យម | គ្រាន់បើ | ធូរធា |
| អត្រាស្ត្រីមានផ្ទៃពោះដែលបានទទួលសេវា( ANC )ពីបុគ្គលិកសុខាភិបាល | ៨៩,៧ | ៩៤,៧ | ៩៦,២ | ៩៨,១ | ៩៩,៣៣ |
| អត្រាស្ត្រីដែលមានទារកចុងក្រោយបានចាក់វ៉ាក់សាំងបង្កាជំងឺតេតាណូស | ៨៣,២ | ៨៧,៥ | ៨៧,៣ | ៩២,៤ | ៩៣,៥ |
| សមាមាត្រនៃការសម្រាលនៅ មូលដ្ឋានសុខភិបាល | ៦៨,៤ | ៧៨,៨ | ៨៦,៨ | ៩០,៨ | ៩៥,៩ |
| អត្រានៃការសម្រាលដោយបុគ្គលិកសុខាភិបាល | ៧៥,២ | ៨៧,០ | ៩២,៧ | ៩៦,៥ | ៩៨,៤ |
| អត្រាស្ត្រីមានផ្ទៃពោះដែលបានទទួលសេវា( PNC )ពីរថ្ងៃបន្ទាប់ពីសម្រាលកូនរួច | ៨៤,៣ | ៨៧,៥ | ៩៣,៦ | ៩២,២ | ៩៥,៦ |

ប្រភព៖ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ ២០១៤

## ៦.ក្របខ័ណ្ឌគោលនយោបាយ

ដើម្បីធ្វើឲ្យប្រសើរឡើងនូវសេវាសុខភាពមាតា និងទារក គោលនយោបាយមួយចំនួនត្រូវបានអនុវត្តដោយរដ្ឋាភិបាលក្រោមការឧបត្ថម្ភពីដៃគូរពាក់ព័ន្ធ។ រដ្ឋាភិបាលបានអនុម័តក្របខណ្ឌ SDG3 ក្នុងឆ្នាំ ២០១៥ ជាមួយនឹងគោលបំណងកាត់បន្ថយអត្រាមរណៈមាតា និងទារក និង SDG5 ក្នុងទិសដៅលើកកម្ពស់សមភាព និងការផ្តល់

ភាពអង់អាចដល់ស្ត្រី។ ការអភិវឌ្ឍវិស័យសុខាភិបាល ជាពិសេសការពង្រឹងសេវាសុខភាពមាតា និងទារក ត្រូវបានចាត់ជាវិស័យអាទិភាពមួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ(NSDP)។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) ថ្មីបំផុត ឆ្នាំ ២០១៩-២០៣០ ផ្តោតជាសំខាន់ទៅលើ (១)សុខភាពបន្តពូជ សុខភាពមាតា និងទារក និងអាហារូបត្ថម្ភ (២)កាត់បន្ថយអត្រាមរណៈភាព និងអត្រាមរណៈភាពពីជំងឺឆ្លង និងជំងឺមិនឆ្លង និង(៣) ការធានាឲ្យបាននូវសមធម៌ក្នុងការទទួលបានសេវាសុខភាពសម្រាប់ប្រជាជនទាំងអស់ [33, 46]។ NSDP បានផ្តល់ក្របខ័ណ្ឌដើម្បីបង្កើនផែនការយុទ្ធសាស្ត្រសុខាភិបាល (HSP)។

ផែនការ HSP ត្រូវបានរៀបចំ និងអនុវត្តជាបន្តបន្ទាប់។ HSP ថ្មីបំផុត ឆ្នាំ ២០១៦-២០២០ សង្កត់ធ្ងន់លើការធ្វើឲ្យប្រសើរឡើងនូវសេវាថែទាំសុខភាព និងបង្កើនសេវាគាំពារហិរញ្ញវត្ថុសុខភាពសម្រាប់ប្រជាជន[45]។ សុខភាពបន្តពូជ និងសុខភាពមាតា និងទារក ជាវិស័យអាទិភាពសម្រាប់ការលើកកម្ពស់សុខភាពស្ត្រី ក្នុងគោលនយោបាយ HSP ។ ចំណុចផ្តោតរបស់សេវាលើកកម្ពស់សុខភាពមាតា និងទារក គឺលើការរំលូតកូនដោយសុវត្ថិភាព ការមានផ្ទៃពោះក្នុងវ័យជំទង់ សេវាថែទាំគភ៌មុនសម្រាល ពិនិត្យថែទាំក្រោយសម្រាល និងការការពារការចម្លងមេរោគអេដស៍ពីម្តាយទៅកូន[60]។ ផ្នែកដែលសំខាន់មួយទៀតគឺ ការអនុវត្តកម្មវិធីផែនទីចង្អុលបង្ហាញសម្រាប់ការកាត់បន្ថយអត្រាមរណៈភាពមាតា និងទារក(FTIRM) ដែលបានអនុវត្តចាប់តាំងពីឆ្នាំ ២០១៦-២០២០ ក្នុងគោលបំណងធានាឲ្យបាននូវប្រសិទ្ធភាពក្នុងការប្រតិបត្តិសេវាលើកកម្ពស់សុខភាពមាតា និងទារក។ គម្រោងនេះរួមមាន (១)ការបន្ថែមនូវបុគ្គលិកសម្រាលដែលមានជំនាញ (២)សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងថែទាំទារកទើបកើត (៣)ការថែទាំទារកទើបនឹងកើត (៤) ផែនការគ្រួសារ (៥)ការរំលូតកូនដោយសុវត្ថិភាព (៦)លុបបំបាត់របាំងហិរញ្ញវត្ថុដើម្បីបង្កើនការទទួលបានសេវាសុខភាព និង (៧)ការផ្លាស់ប្តូរឥរិយាបទក្នុងការទំនាក់ទំនង[ii] [61]។ បន្ថែមពីលើនេះទៀត ផែនការជាតិសម្រាប់គុណភាពសេវាសុខាភិបាលត្រូវបានអនុវត្ត ហើយប្រើប្រាស់ជាផែនទីចង្អុលផ្លូវសម្រាប់បង្កើតស្តង់ដាអប្បរមា និងជាគោលសម្រាប់ប្រពន្ធ័សុខភាព [45]។

នៅក្នុងផែនការ HSP ក្រសួងសុខាភិបាលក៏បានកំពុងអនុវត្តកម្មវិធីហិរញ្ញប្បទានសុខាភិបាលមួយចំនួនសម្រាប់ជនក្រីក្រផងដែរ។ ទាំងនេះរួមបញ្ចូល (១)ការមិនគិតថ្លៃសេវា (២)កម្មវិធីមូលនិធិសមធម៌ (៣)ប័ណ្ណសេវាសុខភាពបន្តពូជ (៤)ការធានារ៉ាប់រងសុខភាពសហគមន៍[33, 46]។ គម្រោងប្រាក់ឧបត្ថម្ភលើកទឹកចិត្តធ្មបសម្រាប់កំណើតរស់ត្រូវបានចាត់ទុកជាកត្តាដែលជំរុញឲ្យមានការប្រើប្រាស់សេវាសម្រាលកូននៅតាមមន្ទីរពេទ្យ ឬមណ្ឌលសុខភាពរដ្ឋ[46]។ ការធានាឲ្យបានការទទួលបានសេវាថែទាំសុខភាពមាតា និងទារកក៏បានបញ្ជាក់នៅក្នុងគោលនយោបាយពាក់ពន្ធ័ ដូចជា ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ របស់ក្រសួងកិច្ចការនារី [4]។

[ii] សំដៅទៅលើការធ្វើឲ្យប្រសើរឡើងនូវការថែទាំសុខភាពបុគ្គល គ្រួសារ និងការទទួលបានសេវាថែទាំសុខភាពសម្រាប់ស្ត្រីតាមរយៈការផ្តោតលើការបង្កើនការប្រើប្រាស់ ANC និង PNC ការជំរុញការបំបៅកូនដោយទឹកដោះ ការថែរក្សាទារកទើបនឹងកើតឲ្យបានត្រឹមត្រូវ កាត់បន្ថយការមានផ្ទៃពោះក្នុងវ័យជំទង់ កាត់បន្ថយនូវការប្រើប្រាស់ការធ្វើផែនការគ្រួសារបែបប្រពៃណី និងកាត់បន្ថយការរំលូតកូនដែលពុំមានសុវត្ថិភាពនិងញឹកញាប់ ។

## III. សេដ្ឋកិច្ច ការចូលរួមកម្លាំងពលកម្ម និងភាពជាសហគ្រិនស្រ្តី

ផ្នែកនេះនឹងពិនិត្យមើលទៅលើវិស័យសេដ្ឋកិច្ចក្នុងប្រធានបទ «ការផ្តល់ភាពអង់អាចដល់ស្រ្តីនៅកម្ពុជា»។ ខណៈពេលដែលប្រធានបទនៃការស្រាវជ្រាវនេះបានផ្សារភ្ជាប់ជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៥ (SDG៥) ការទាក់ទងគ្នារបស់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពមានន័យថាគោលសំដៅផ្សេងៗទៀតក៏ពាក់ព័ន្ធគ្នាដែរទៅនឹងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្រ្តី(WEE)៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ (SDG៤) ផ្តោតទៅលើការអប់រំដែលមានលក្ខណៈបញ្ចូលគ្នា និងប្រកបដោយសមធម៌ ហើយគោលដៅមួយទៀតគឺ ដើម្បីបង្កើនការបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងកម្មវិធី បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ (ICT) និងកម្មវិធីវិទ្យាសាស្រ្ត ដែលត្រូវបានរំពឹងទុកថានឹងផ្លាស់ប្តូរទីផ្សារការងារនៅប្រទេសកម្ពុជា និង «បដិវត្តឧស្សាហកម្មទីលើកទី៤»។ លើសពីនេះទៀត គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៩ (SDG៩) ផ្តោតទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធ ការលើកកម្ពស់ការរួមបញ្ចូល និងចីរភាពឧស្សាហូបនីយកម្មច្នៃប្រឌិតថ្មី ដែលបង្ហាញពីតម្រូវការនៃការចូលរួមពីស្រ្តីក្នុងឧស្សាហូបនីយកម្ម និងបដិវត្តឧស្សាហកម្មលើកទី៤ ដូចដែលបានរៀបរាប់ខាងលើ។

ក្រៅពីទិដ្ឋភាពសង្ខេបនៃការចូលរួមកម្លាំងពលកម្មរបស់ស្រ្តី និងសហគ្រិនភាពស្រ្តី ផ្នែកនេះនឹងធ្វើការពិនិត្យសង្ខេបទៅលើ «បដិវត្តឧស្សាហកម្មលើកទី៤» ហើយតើទស្សនៈនេះមានន័យយ៉ាងដូចម្តេចសម្រាប់ស្រ្តីនៅក្នុងសេដ្ឋកិច្ចកម្ពុជា។

### ១. កម្លាំងពលកម្មកម្ពុជា៖ នៅក្មេងខ្ចី ហើយត្រូវប្រកួតប្រជែងជាមួយអាស៊ាន

ប្រទេសកម្ពុជាមានប្រជាជនវ័យក្មេង ដែលសបញ្ជាក់ឲ្យឃើញថា រៀងរាល់ឆ្នាំមានបុគ្គលិកដែលប្រកបដោយសក្តានុពលថ្មីចូលរួមក្នុងទីផ្សារការងារ។ ទាំងនេះអាចធ្វើឲ្យមានការលំបាកក្នុងការធានាថា មានការងារសមរម្យសម្រាប់មនុស្សគ្រប់គ្នា [62, 63]។ ការងារសមរម្យ គឺជាការងារដែលមានប្រាក់ចំណូលសមរម្យ និងផ្តល់នូវសុវត្ថិភាព។ ផ្ទុយពីការងារសមរម្យ គឺការងារងាយរងគ្រោះដែលជាការងារផ្ទាល់ខ្លួន ឬការងារគ្រួសារដែលមិនមានប្រាក់ឈ្នួល [62]។ បន្ថែមលើកម្លាំងពលកម្មដែលកំពុងតែកើនឡើង អាស៊ានកំពុងខិតខំធ្វើឲ្យប្រសើរឡើងនូវសមាហរណកម្មក្នុងតំបន់នាពេលអនាគត ដែលមានន័យថា ពលករកម្ពុជានឹងត្រូវប្រកួតប្រជែងជាមួយនឹងកម្លាំងពលកម្មដែលមានជំនាញខ្ពស់ដែលមកពីបណ្តាប្រទេសអាស៊ានផ្សេងៗទៀត[62]។ បញ្ហាប្រឈមទាំងនេះ ជះឥទ្ធិពលលើស្រ្តីច្រើនជាងបុរស ព្រោះស្រ្តីមានជំនាញការងារទាប និងមានកម្រិតនៃការអប់រំទាបជាងបុរស[64]។ អង្គការសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) បានធ្វើការកំណត់ថាកំរិតនៃការអប់រំមិនស្មើគ្នានៅទូទាំងរដ្ឋជាសមាជិកអាស៊ាន គឺជាបញ្ហាប្រឈមចម្បងមួយសម្រាប់អ្នកធ្វើគោលនយោបាយនៅក្នុងតំបន់ ជាពិសេសទាក់ទងទៅនឹងសហគ្រិនភាពនៅក្នុងតំបន់[65]។ ទាំងនេះមានសារៈសំខាន់ណាស់សម្រាប់ស្រ្តី ជាពិសេសដោយសារស្រ្តីនៅក្នុងប្រទេសកម្ពុជា (ក៏ដូចជានៅតាមបណ្តាប្រទេសអាស៊ានផ្សេងទៀតដែរ) មានមានទំនោរជាសហគ្រិនច្រើនជាងបុរស បើទោះបីជាអាជីវកម្មធន់តូចក៏ដោយ។ សូមមើលតារាងទី៥ សម្រាប់ទិដ្ឋភាពទូទៅនៃភាពជាសហគ្រិនតាមយេនឌ័រ។

*តារាង 1៖ទិដ្ឋភាពទូទៅនៃភាពជាសហគ្រិនតាមយេនឌ័រ*

| សកម្មភាពអាជីវកម្ម | ចំនួនសហគ្រាស សរុប | បុរសជាម្ចាស់ | ស្ត្រីជាម្ចាស់ |
|---|---|---|---|
| សហគ្រាសសរុប | ៥០៥,១៣៤ (១០០%) | ១៧៦,១២៨ (៣៤.៩%) | ៣២៩,០០៦ (៦៥.១%) |
| លក់ដុំ និងរាយ | ២៨៩,១៣០ (៥៧.២%) | ៧៣,៥១៦ (១៤.៦%) | ២១៥,៦១៤ (៤២.៧%) |
| សេវាកម្មស្នាក់នៅ និងអាហារ | ៦៩,៥៦៩ (១៣.៨%) | ១៤,៦១២ (២.៩%) | ៥៤,៩៥៧ (១០.៩%) |
| ផលិតកម្ម | ៧៥,០៣១ (១៤.៩%) | ៣៩,៩៩៨ (៧.៩%) | ៣៥,០៣៣ (៦.៩%) |
| ផ្សេងទៀត | ៧១,៤០៤ (១៤.១%) | ៤៨,០០២ (៩.៥%) | ២៣,៤០២ ៤.៦%) |

*ប្រភព៖ ក្រសួងកិច្ចការនារី [63] ជាមួយទិន្នន័យពីជំរឿនសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០១១។*

## ២. បដិវត្តឧស្សាហកម្មលើកទី៤

ការផ្លាស់ប្តូរដ៏គួរឲ្យកត់សម្គាល់មួយទៀតសម្រាប់សេដ្ឋកិច្ចកម្ពុជា និងសេដ្ឋកិច្ចនៅទូទាំងពិភពលោកគឺ «បដិវត្តឧស្សាហកម្មលើកទី៤»។ យោងតាមអត្ថបទសិក្សា និងគោលនយោបាយផ្សេងៗគ្នា ពាក្យបដិវត្តឧស្សាហកម្មលើកទី៤ ត្រូវបានគេហៅតាមលក្ខខណ្ឌផ្សេងៗគ្នារួមមាន៖ ឧស្សាហកម្ម ៤.០, 4IR, FIRe, IIoT (ឬអ៊ិនធឺណិតឧស្សាហកម្ម)។ សម្រាប់ការសិក្សានេះនឹងប្រើពាក្យ «បដិវត្តឧស្សាហកម្មលើកទី៤» ពីព្រោះវាមានលក្ខណៈទូទៅនៅក្នុងឯកសារគោលនយោបាយ (ប្រើប្រាស់ដោយអង្គការពលកម្មអន្តរជាតិ និងវេទិកាសេដ្ឋកិច្ចពិភពលោក)។ បដិវត្តឧស្សាហកម្មបង្ហាញពីការបំបែកចេញនូវការអនុវត្តអាជីវកម្ម ខណៈពេលដែលការបង្កើតថ្មីមួយចំនួន ធ្វើឲ្យការអនុវត្តនៅពេលបច្ចុប្បន្នកាន់តែមានប្រសិទ្ធិភាព បច្ចេកវិទ្យាថ្មីៗ និងការជឿនលឿនថ្មីៗនឹងផ្លាស់ប្តូរយ៉ាងខ្លាំងនូវរបៀបដែលអាជីវកម្មធ្វើប្រតិបត្តិការនៅក្នុងសេដ្ឋកិច្ច។ ការបោះពុម្ព 3D ត្រូវបានគេចាត់ទុកថាជាផ្នែកមួយនៃបច្ចេកវិទ្យាថ្មី។ «អ៊ីនធឺណេតនៃអ្វីៗ (Internet of Things)» ឬ IoT ដែលសំដៅទៅលើឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃដែលអាចភ្ជាប់ទៅសេវាអ៊ីនធឺណេត សិប្បនិម្មិតវៃឆ្លាត(AI) «ទិន្នន័យទំហំធំ» ដែលជាវិស័យទាក់ទងនឹងការវិភាគទិន្នន័យស្មុគស្មាញ ឧទាហរណ៍ បណ្តាញផ្សព្វផ្សាយសង្គម និងសេដ្ឋកិច្ចតាមតំរូវការ ដែលជាសេដ្ឋកិច្ចបង្កើតឡើងដោយទីផ្សារឌីជីថល ឧទាហរណ៍ កម្មវិធីសម្រាប់កក់តាក់ស៊ី ឬរ៉ឺម៉កនៅកម្ពុជា [66]។

តាមការសិក្សា (ក៏ដូចជាក្នុងវេទិកាសេដ្ឋកិច្ចពិភពលោក និងអង្គការសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការសេដ្ឋកិច្ច៖ OECD) បានព្យាករណ៍ថា បច្ចេកវិទ្យាទាំងអស់នេះនឹងនាំឲ្យមានការបង្កើត «រោងចក្រវៃឆ្លាត» ដែលជាការចម្លងនៃរោងចក្រពិភពលោកពិត។ ទាំងនេះនឹងអនុញ្ញាតឲ្យមានការសម្រេចចិត្តបែបវិមជ្ឈការ។ ទាំងនេះក៏អាចមានន័យថាផលិតកម្មមានភាពបត់បែនជាងមុន ហើយអាចឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងនិន្នាការ

អាជីវកម្ម និងការផ្លាស់ប្តូរភ្លាមៗ ហើយនោះគឺជាការច្នៃប្រឌិតដែលផលិតផលផលិតឡើងមានគោលបំណងតម្រូវតាមតម្រូវការអតិថិជន [67]។

ខណៈពេលដែលទាំងនេះអាចនាំមកនូវឱកាសជាច្រើន ដូចជា ការផ្លាស់ប្តូរដ៏កំហុកនៃរបៀបប្រតិបត្តិការអាជីវកម្មក៏អាចនាំមកនូវផលប៉ះពាល់អវិជ្ជមានផងដែរ។ ពេលនៅដែលបច្ចេកវិទ្យាកាន់តែប្រសើរឡើងក្នុងការឆ្លើយតបនឹងសកម្មភាពរបស់មនុស្ស (ឧទាហរណ៍សិប្បនិម្មិតវៃឆ្លាត) កម្មករជាច្រើននឹងត្រូវផ្លាស់ទីកន្លែង ជាពិសេសកម្មករដែលបំពេញភារកិច្ចជាប្រចាំ។ នេះមានន័យថា ការផ្តល់កម្លាំងពលកម្មទាបនឹងមិនមានប្រសិទ្ធភាពសម្រាប់ជាយុទ្ធសាស្ត្រដើម្បីទាក់ទាញការវិនិយោគក្នុងផលិតកម្មឡើយ[66, 68]។ មានការចង្អុលបង្ហាញមួយចំនួនថានិន្នាការមួយបានចាប់ផ្តើមផ្លាស់ប្តូរផលិតកម្មឲ្យត្រឡប់ទៅប្រទេសអ្នកមានដូចជានៅអាមេរិកខាងជើង និងអឺរ៉ុប [68]។

សរុបមក ឧស្សាហកម្មលើកទី៤ គឺជាការផ្លាស់ប្តូរដ៏ធំមួយក្នុងដំណើរការការងារ ដែលអាចផ្តល់នូវឱកាសក៏ដូចជាបញ្ហាប្រឈម។ បច្ចេកវិទ្យាថ្មីនេះអាចធ្វើឲ្យស្ត្រីមានភាពងាយស្រួលក្នុងការចូលរួមក្នុងទីផ្សារការងារ។ ឧទាហរណ៍៖ គំរូការងារដែលអាចបត់បែនបាន «រោងចក្រវៃឆ្លាត» អាចនាំឲ្យស្ត្រីមានតុល្យភាពកាន់តែប្រសើរជាមួយនឹងជីវិតការងារ និងជីវិតផ្ទាល់ខ្លួន [69, 70]។ ទោះបីជាយ៉ាងណាក៏ដោយ វាក៏ជាការព្រួយបារម្ភខ្លះផងដែរថាការផ្លាស់ប្តូរនេះអាចនឹងធ្វើឲ្យបាត់បង់វិសមភាព។ ដោយសារការចូលរួមក្នុងទម្រង់ការងារថ្មីទាំងនេះពឹងផ្អែកលើការប្រើប្រាស់ ចំណេះដឹងផ្នែកបច្ចេកវិទ្យា សម្រាប់អ្នកដែលមគ្គានមធ្យោបាយភ្ជាប់បច្ចេកវិទ្យាអាចនឹងមិនទទួលបានអត្ថប្រយោជន៍ច្រើនទេ ហើយភាគច្រើនគឺជាស្ត្រី។ នេះត្រូវបានគេហៅថា «ការបែងចែកឌីជីថល» ហើយបណ្តាលមកពីការរួមបញ្ចូលគ្នាដោយគ្មានការចូលនៃរាងកាយ និងកង្វះខាតនៃជំនាញក្នុងការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងគមនាគមន៍ (ICT)គន្លាតទាំងពីរនេះពង្រឹងគ្នាទៅវិញទៅមក ដោយគ្មានការចូលរួមរាងកាយ អ្នកមិនអាចអនុវត្តជំនាញ និងដោយគ្មានជំនាញអ្នកទំនងជាមិនមានលទ្ធភាពចូលរួមដោយផ្ទាល់ទេ [69, 71]។ ពេលដែលស្ត្រីមានកម្រិតអប់រំទាប និងមានអារម្មណ៍មិនសូវមានទំនុកចិត្តលើជំនាញឌីជីថលរបស់ពួកគេផងនោះ វានឹងមានហានិភ័យដែលពួកគេមួយចំនួនអាចត្រូវបានគេ «ទុកចោល» នៅក្នុងបដិវត្តឧស្សាហកម្មលើកទី៤ [63, 64]។

### ៣. បង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (WEE)

បង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (WEE) ត្រូវបាន OECD ឲ្យនិយមន័យថា៖

> *«សមត្ថភាពរបស់ស្ត្រី និងបុរសក្នុងការចូលរួមចំណែក និងការទទួលបានអត្ថប្រយោជន៍ពីដំណើរការនៃការលូតលាស់តាមរយៈដែលអាចត្រូវបានទទួលស្គាល់តម្លៃនៃការចូលរួមចំណែករបស់ពួកគេ គោរពសេចក្តីថ្លៃថ្នូររបស់ពួកគេ និងធ្វើឲ្យតាមរយៈវិធីណាក៏ដោយត្រូវតែមានការចរចារមួយដែលស្មើភាពអំពីការទទួលបានអត្ថប្រយោជន៍នៃការរីកចំរើន។ ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចបង្កើនការទទួលបានធនធាននិងឱកាសសេដ្ឋកិច្ចសម្រាប់ស្ត្រីរួមមាន ការងារសេវាកម្ម ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ ឬទ្រព្យសម្បត្តិផលិតភាព ការអភិវឌ្ឍជំនាញ និងព័ត៌មានទីផ្សារ»។ [72, p. 6]*

និយមន័យនេះផ្សំឡើងដោយសាមាសធាតុបីរួមមាន៖ ការចូលរួមចំណែកនៅក្នុងការរីកចំរើន ការទទួលបានអត្ថប្រយោជន៍និងការផ្តល់វិភាគទានក្នុងការរីកចំរើន និងសមត្ថភាពក្នុងការសម្រេចចិត្តនិងការចរចារដោយយុត្តិធម៌។ ទិដ្ឋភាពទាំងបីនេះក៏អាចរកឃើញផងដែរ នៅក្នុង «នារីរតនៈ» ដែលជាផែនការយុទ្ធសាស្រ្តរយៈពេល ៥ ឆ្នាំរបស់ក្រសួងកិច្ចការនារី (MoWA) មានគោលបំណងសំខាន់ក្នុងការផ្តល់សិទ្ធិដល់ស្ត្រីក្នុងការសំរេចចិត្ត និងធ្វើឲ្យពួកគេអាចទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម [62]។

ខណៈពេលដែលមានការជជែកវែកញែកលើការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីថា ជាញឹកញាប់ត្រូវបានផ្អែកលើតម្លៃ ប៉ុន្តែសេដ្ឋកិច្ចបានរកឃើញថាជាហេតុផលមួយដើម្បីលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចផងដែរ។ តាមការស្រាវជ្រាវរបស់អង្គការពលកម្មអន្តរជាតិ(ILO) ស្នើឲ្យ មានស្ត្រីកាន់តែច្រើនចូលរួមក្នុងតួនាទីជាអ្នកដឹកនាំ ដែលអាចកាត់ការបាត់បង់បុគ្គលិក និងអាចបង្កើនផលិតភាពនៃការងារ[73, 74]។ លើសពីនេះទៀត ការចូលរួមរបស់ស្ត្រីមានន័យថា មានជម្រើសដែលបានទេពកោសល្យច្រើនជាងមុនក្នុងការជ្រើសរើសបុគ្គលិក។ ដូចដែលរបាយការណ៍របស់វេទិកាសេដ្ឋកិច្ចពិភពលោកបានសរសេរថា «ទេពកោសល្យរបស់ស្ត្រីនៅតែជាធនធានអាជីវកម្មមួយ ដែលប្រើប្រាស់មិនចេះគ្រប់គ្រាន់» [70, p. 1]។ អត្ថប្រយោជន៍សម្រាប់សង្គមផ្សេងមួយទៀត គឺនៅពេលដែលមានចំនួនស្ត្រីនៅក្នុងមុខតំណែងគ្រប់គ្រងកាន់តែច្រើន វាអាចផ្សារភ្ជាប់ជាមួយនឹងការប្រយុទ្ធប្រឆាំងនឹងការយាយីផ្លូវភេទនៅកន្លែងធ្វើការ ហើយអត្ថប្រយោជន៍នៃចីរភាពសេដ្ឋកិច្ចនេះ ក៏ផ្តល់ឱកាសឲ្យស្ត្រីអាចជៀសផុតពីការជួញដូរក៏ដូចជាអំពើហិង្សាក្នុងគ្រួសារ [63]។

ខាងក្រោមនេះគឺ ជាស្ថានភាព និងបញ្ហាប្រឈមដែលត្រូវបានគូសបញ្ជាក់ខ្លីៗដែលទាក់ទងនឹងសមាសធាតុទាំងបីនៃការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅប្រទេសកម្ពុជា



ការចូលរួមចំណែក

- អត្រានៃការចូលរួមរបស់ស្ត្រីបានកើនឡើងគួរឲ្យកត់សម្គាល់ក្នុងចន្លោះឆ្នាំ ២០០០ ដល់យ៉ាងហោចណាស់ឆ្នាំ ២០១៥ [62, 63] ប៉ុន្តែអាចនឹងមិនកើនឡើងបន្ថែមនៅប៉ុន្មានឆ្នាំក្រោយៗនេះ [74]។
- ប្រទេសអាស៊ានទទួលបានពិន្ទុខ្ពស់លើការលើកកំពស់សមភាពយេនឌ័រនៅពេលសំដៅ ដល់ភាពជាសហគ្រិន [75, 76] នេះអាចជះឥទ្ធិពលយ៉ាងខ្លាំងទៅលើទីផ្សារការងារដោយសារការស្រាវជ្រាវបានបង្ហាញថាសហគ្រិនស្ត្រីជ្រើសរើសស្ត្រីមកធ្វើការច្រើនជាងបុរស[77]។
- ទោះយ៉ាងណាក៏ដោយ សហគ្រិនស្ត្រីទំនងជាមានអាយុច្រើនជាងសហគ្រិនបុរស ហើយមានលទ្ធភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ (ICT) និងបណ្តាញអាជីវកម្មតិចជាងបុរស ហើយទទួលបានព័ត៌មាន និងបើកអាជីវកម្មខ្នាតតូចជាងបុរស[63, 64]
- ស្ត្រីដែលធ្វើការក្នុង«ការងារងាយរងគ្រោះ» កំពុងមានចំនួនថយចុះ ប៉ុន្តែមិនលឿនដូចបុរសទេ។ ស្រដៀងគ្នានេះដែរ បុរសនៅប្រទេសកម្ពុជាកំពុងងាកចេញពីវិស័យកសិកម្ម (កសិកម្មនិងនេសាទ) លឿនជាងស្ត្រី [62]។
- ឧបសគ្គចំបងក្នុងការចូលរួមកម្លាំងពលកម្មរបស់ស្ត្រីគឺ «ពេលវេលាមិនគ្រប់គ្រាន់» ព្រោះពួកគេមានទំនួលខុសត្រូវមើលថៃគ្រួសារ ដែលជាផងពិបាកក្នុងការធ្វើការពេញម៉ោងបំពេញភារកិច្ចទាំងនោះ[64]។



**អត្ថប្រយោជន៍ និងការផ្តល់វិភាគទាន**

- ការចូលរួមរបស់ស្ត្រីនៅក្នុងកម្លាំងពលកម្ម គឺជាឱកាសប្រកបដោយភាពច្នៃប្រឌិតសម្រាប់អាជីវកម្ម ព្រោះវាអាចពង្រីកសមត្ថភាពទេពកោសល្យ [70]។
- ស្ត្រីជាមធ្យមទទួលបានប្រាក់ឈ្នួលតែ ៨០ភាគរយ បើប្រៀបធៀបនឹងរបស់បុរស [62, 63] ដោយសារតែពួកគេទំនងជាប្រកបការងារងាយរងគ្រោះ (៧០ភាគរយ នៃស្ត្រីនឹង ៥៩ភាគរយ នៃបុរស) ហើយជារឿយៗធ្វើការនៅក្នុងវិស័យដែលផ្តល់ប្រាក់ឈ្នួលទាប [74]។
- ស្ត្រីធ្វើចំណាកស្រុកដើម្បីធ្វើការច្រើនជាងបុរស។ ជនចំណាកស្រុកជាស្ត្រីមានប្រាក់ចំណូលទាបជាងបុរស ប៉ុន្តែផ្ញើប្រាក់មកផ្ទះច្រើនជាងបុរស ដូច្នេះហើយពួកគេនៅសល់ផ្ទាល់ខ្លួនតិចតួចជាងបុរស [62]។
- ៦៥ភាគរយ នៃអាជីវកម្មគឺជាកម្មសិទ្ធិរបស់ស្ត្រី ប៉ុន្តែវាជាអាជីវកម្មខ្នាតតូច។ ក្នុងចំណោមសហគ្រាសដែលជាកម្មសិទ្ធិរបស់ស្ត្រី ៥១ ភាគរយ មានអ្នកចូលរួមតែម្នាក់ និង ៩៦ភាគរយ មានអ្នកចូលរួម ៤ នាក់ឬតិចជាងនេះ [62, 63]។
- សហគ្រិនស្ត្រីមាននិន្នាការធ្វើប្រតិបត្តិការក្នុងវិស័យដែលបន្ថែមតម្លៃតិចតួចដល់សង្វាក់ផ្គត់ផ្គង់ និងមានទីផ្សារក្នុងស្រុក (មិនមែនអន្តរជាតិ) [63, 64]។



**សមត្ថភាពក្នុងការសំរេចចិត្ត**

- ស្ត្រីអាចប្រើប្រាស់បណ្តាញទំនាក់ទំនងអាជីវកម្មតិចជាងបុរស [62]
- ស្ត្រីទំនងជាក្លាយជាសមាជិកសហជីពច្រើនជាងបុរស ដោយសារតែភាគច្រើន មានអត្រាខ្ពស់នៃការបង្កើតសហជីពនៅក្នុងវិស័យកាត់ដេរ (ប្រហែល ៣៨%) ដែលមានស្ត្រីធ្វើការច្រើនជាងបុរស [62]។
- ឧបសគ្គធំៗពីរដែលរាំងស្ទះក្នុងការបង្កើនភាពអង់អាចសេដ្ឋកិច្ចរបស់ស្ត្រី គឺដោយសាស្ត្រីមានកម្រិតនៃការអប់រំទាប និងរងការរើសអើងក្នុងការអនុវត្តការងារ[64] ។
- មាត្រា១៨២ និងមាត្រា១៨៣ នៃច្បាប់ស្តីពីការងារកម្ពុជា ចែងអំពីការការពារសិទ្ធិរបស់ស្ត្រីមានផ្ទៃពោះ ហើយការអនុវត្តតាមច្បាប់មានកម្រិតខ្ពស់ ប៉ុន្តែបើតាមការសិក្សារបស់អង្គការពលកម្មអន្តរជាតិ(ILO) បានចង្អុលបង្ហាញថា មានការប្រើប្រាស់ល្បិចបញ្ឆោតដើម្បីរើសអើងស្ត្រីមានផ្ទៃពោះ ។
- និយោជកដែលមាននិយោជិកជាស្ត្រីច្រើនជាង ១០០ នាក់ត្រូវតែមានបន្ទប់សម្រាប់បំបៅកូននិងទារកដ្ឋាន (ច្បាប់ការងារ១៨៦)។ ទោះជាយ៉ាងណាក៏ដោយ តាមការសិក្សារបស់អង្គការពលកម្មអន្តរជាតិ(ILO)បានរកឃើញថា រោងចក្រក្នុងប្រទេសកម្ពុជាមិនប្រតិបត្តិតាមមាត្រាមួយនេះឡើយ ។ នេះគឺជាការព្រួយបារម្ភមួយ ព្រោះការរួមបញ្ចូលគ្នារវាងការងារ និងការយកចិត្តទុកដាក់ គឺជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់ស្ត្រីធ្វើការនៅកម្ពុជាជាច្រើន[64, 74]។

## ៤. ជម្រើសគោលនយោបាយ

ការពិនិត្យលើឯកសារពាក់ពន្ធ័នានា បានផ្តល់យោបល់ផ្សេងៗគ្នាដល់អ្នកធ្វើគោលនយោបាយដើម្បីធ្វើការពិចារណា លើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ ខាងក្រោមនេះជាសេចក្តីសង្ខេបនៃយោបល់មួយចំនួនសម្រាប់ជាជម្រើសគោលនយោបាយដែលបានមកពី ឯកសារពាក់ពន្ធ័នានា៖

- ដើម្បីដោះស្រាយនូវបញ្ហាប្រឈម និងឱកាសនានាដែលបានមកពី កំណើនកម្លាំងពលកម្ម និង បច្ចេកវិទ្យាថ្មីៗ OECD បានបញ្ជាក់ឲ្យ រដ្ឋនានានៃសមាជិកអាស៊ាន ASEAN បន្តវិនិយោគលើការអប់រំ និងធ្វើសមាហរណកម្មប្រព័ន្ធអប់រំអាស៊ាន ASEAN មួយ (ដើម្បីកាត់បន្ថយវិសមភាពរវាងរដ្ឋសមាជិកអាស៊ាន [65]
- ក្រសួងកិច្ចការនារី MoWA បានលើកឡើងថា ការបង្កើតការងារ ជាពិសេសសម្រាប់កម្មករដែលមានជំនាញទាបជាចាំបាច់ដើម្បីឆ្លើយតបទៅនឹងកំណើនកម្លាំងពលកម្ម[63]
- ទាំងគណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក (UNESCAP) និង ឯកសារពាក់ព័ន្ធដ៏ទៃទៀត បានបញ្ជាក់ថា ការបំបែកទិន្នន័យបែងចែកតាមភេទឲ្យបានកាន់តែលម្អិតជាងមុន និងអាចផ្តល់ព័ត៌មានកាន់តែប្រសើរឡើងសម្រាប់គោលនយោបាយ។ ជាពិសេស ស្ថិតិយេនឌ័រ ស្តីពី ការប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ICT និងជំនាញបច្ចេកវិទ្យា ICT មានការខ្វះខាតនៅឡើយ (នៅក្នុងប្រទេសអាស៊ានទាំងអស់លើកលែងតែប្រទេសថៃ និងសិង្ហបុរី) [64, 69]
- ក្រសួងកិច្ចការនារី (MoWA) បានលើកសំណូមពរឲ្យមានកិច្ចសហប្រតិបត្តិការបន្ថែមទៀតរវាងរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធក្នុងទីផ្សារការងារដែលរួមមាន សមាគមន៍រោងចក្រកាត់ដេរនៅកម្ពុជា (GMAC) អង្គការពលកម្មអន្តរជាតិ (ILO) និងអង្គការក្នុងវិស័យឯកជន[63]។ របាយការណ៍វេទិកាសេដ្ឋកិច្ចពិភពលោក ក៏បានបញ្ជាក់ថា ភាពជាដៃគូឯកជនសាធារណៈ និងកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិលដែលផ្តោតទៅលើសិទ្ធិយេនឌ័រ ជាមធ្យោបាយមួយដើម្បីលើកកម្ពស់គុណភាពយេនឌ័រនៅលើទីផ្សារការងារ[70]។
- ក្រសួងកិច្ចការនារី (MoWA) ក៏បានរៀបរាប់ពីលទ្ធភាពនៃកម្មវិធីគាំទ្រថវិកាដើម្បីជួយស្ត្រីធ្វើក្នុងការធ្វើកសិកម្មឲ្យកាន់តែមានលក្ខណៈពាណិជ្ជកម្ម ឬដើម្បីបង្កើនសកម្មភាពសេដ្ឋកិច្ចចេញពីកសិដ្ឋាន[63]។
- យុទ្ធនាការសាធារណៈដើម្បីលើកកម្ពស់ការយល់ដឹងអំពីវិធីធ្វើឲ្យមានតុល្យភាពការងារ និងជីវិតឯកជនឬគ្រួសារបានលើកឡើងថាជាជំរើសមួយរបស់ក្រសួងកិច្ចការនារី MoWA [63]។ របាយការណ៍វេទិកាសេដ្ឋកិច្ចពិភពលោក បានសំណូមពរឲ្យមានការលើកទឹកចិត្តក្នុងការថែទាំកុមារឲ្យបានត្រឹមត្រូវ និងដើម្បីបង្កើតគោលការណ៍ណែនាំស្តីពីគោលនយោបាយតុល្យភាពជីវិតការងារ [70] ។
- ជាចុងក្រោយ UNESCAP បានបញ្ជាក់ថា ការបណ្តុះបណ្តាល និងការអប់រំរបស់ស្ត្រីនៅក្នុងសេដ្ឋកិច្ចដែលកំពុងរីកចម្រើន អាចជួយបង្កើតការងារ និងបង្កើនប្រាក់ចំណូល។ ជាពិសេស UNESCAP ណែនាំឲ្យមានការបណ្តុះបណ្តាលលើជំនាញគណនេយ្យ ជំនាញគ្រប់គ្រងទូទៅ ចំណេះដឹងហិរញ្ញវត្ថុ ជំនាញគ្រប់គ្រងធនធានមនុស្ស និងជំនាញទីផ្សារ[64]។

## IV. អំពើហិង្សាលើស្ត្រី

ជំហានសំខាន់ឆ្ពោះទៅរកការសម្រេចសមភាពយេនឌ័រ គឺការលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី។ នេះមិនត្រឹមតែជាបញ្ហារបស់ស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានផលប៉ះពាល់ផងដែរសម្រាប់យើងទាំងអស់គ្នា រួមទាំង

បុរស និងកុមារផងដែរ[78]។ អំពើហិង្សាលើស្ត្រី និងក្មេងស្រី(VAWG) បានក្លាយជាជាប្រវត្តិសាស្ត្រដែលគេមិនសូវនិយាយ ហើយមើលរំលង។ ប៉ុន្តែទោះបីជាយ៉ាងណា បន្ទាប់ពីការតស៊ូមតិជាច្រើនទសវត្ស និងចលនារបស់ស្ត្រី និងកម្មវិធីស្ត្រីនិយម នៅពេលនេះបញ្ហានេះបានក្លាយជាការចាប់អារម្មណ៍ថ្នាក់ជាតិ និងអន្តរជាតិក្នុងការជជែកពិភាគសារជាសាធារណៈ[79]។ អំពើហិង្សាលើស្ត្រី និងក្មេងស្រី ឥលូវនេះត្រូវបានគេទទួលស្គាល់ជាទូទៅថាជាការរំលោភបំពានសិទ្ធិមនុស្សជាមូលដ្ឋាន និងជាបញ្ហាដែលទាក់ទងទៅនឹងការចំណាយសេដ្ឋកិច្ច និងសង្គមយ៉ាងច្រើនដល់បុគ្គលនីមួយៗ សហគមន៍ និងប្រទេសជាតិផងដែរ[80]។

អំពើហិង្សាលើស្ត្រី និងក្មេងស្រី សំដៅទៅលើសកម្មភាពអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងឡាយណាដែលបង្ក ឬបណ្តាលឲ្យមានផលប៉ះពាល់ ឬការឈឺចាប់ដល់រាងកាយ ផ្លូវភេទ និងផ្លូវចិត្តរបស់ស្ត្រី រួមទាំងការគំរាមកំហែងនៃសកម្មភាពបែបបង្ខិតបង្ខំ ឬក៏ការដកហូតនូវសិទ្ធិសេរីភាពតាមទំនើងចិត្ត មិនថាកើតឡើងក្នុងទីសាធារណៈ ឬក្នុងជីវិតឯកជនក៏ដោយ[78]។ អំពើហិង្សាទាក់ទងនឹងយេនឌ័រ លើស្ត្រី និងក្មេងស្រី នៅតែបន្តកើតមានគ្រប់ទម្រង់ទាំងអស់ ក្នុងរូបភាពជាអំពើហិង្សាពីដៃគូស្និទ្ធស្នាល អំពើហិង្សាផ្លូវភេទ រួមទាំងការរំលោភសេពសន្ថវៈ ពេស្យាចារ អាសអាភាស និងការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ កន្លែងសាធារណៈ និងតាមប្រពន្ធ័ អ៊ិនធរណេត ការជួញដូរស្ត្រី និងក្មេងស្រី សកម្មភាពដែលបំផ្លាញ និងការអនុវត្តន៍ដែលបង្កអន្តរាយ ដោយរាប់បញ្ចូលទាំងការ បង្ខំឲ្យរៀបការអាពាហ៍ពិពាហ៍ អាពាហ៍ពិពាហ៍កុមារ និងការកាត់ប្រដាប់បន្តពូជស្ត្រី[81]។ អំពើហិង្សាលើស្ត្រី និងក្មេងស្រី គឺជាបញ្ហាចម្បងមួយដែលកំពុងកើតឡើងក្នុងសង្គមសម័យទំនើប ហើយពិភពលោកក៏មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដែរ ជាពិសេសស្ត្រី និងក្មេងស្រី ដោយសារតែពេលពួកគេងាយរងគ្រោះពីការរំលោភបំពាន និងការកេងប្រវ័ញ្ច។ ទាំងនេះបានធ្វើឲ្យពួកគេមិនអាចទទួលបានសិទ្ធិជាមូលដ្ឋាន និងសេរីភាពពេញលេញឡើយ។ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពគោលដៅទីប្រាំ បានកំណត់យកសូចនាករជាក់លាក់ចំនួនពីរសម្រាប់ការវាស់ស្ទង់លើឥទ្ធិពលនៃគំនិតផ្តួចផ្តើមដែលបានបង្កើតឡើងដើម្បីកាត់បន្ថយការរីករាលដាលនៃអំពើហិង្សាលើស្ត្រីក្នុងនោះអំពើហិង្សាលើដៃគូស្នាលគឺជាផ្នែកមួយដ៏សំខាន់[2]។

អត្រារីករាលដាលនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី កើនគួឲ្យកត់សម្គាល់ ហើយបើយោងទៅតាមអង្គការសុខភាពពិភពលោក (WHO) យ៉ាងហោចណាស់មានស្ត្រី ៣៥ ភាគរយ នៅទូទាំងពិភពលោកធ្លាប់រងអំពើហិង្សាលើរាងកាយ និង/ឬ ផ្លូវភេទនៅក្នុងជីវិតរបស់ពួកគេ រួមទាំងការមានផ្ទៃពោះដែលមិនចង់បាន និងធាប់មានផ្ទៃពោះ[82]។ មានស្ត្រីប្រមាណជា ៣៣ ភាគរយដែលមានទំនាក់ទំនងជាមួយដៃគូរស្និទ្ធស្នាល ធ្លាប់រងអំពើហិង្សាលើរាងកាយ និង/ឬ ផ្លូវភេទពីដៃគូរបស់ពួកគេ[83]។ ទាំងនេះអាចបណ្តាលឲ្យស្ត្រីមិនមានការសម្រេចចិត្តទាក់ទងនឹងការប្រើប្រាស់ថ្នាំពន្យារកំណើតដើម្បីការពារការមានផ្ទៃពោះ និងជំងឺកាមរោគ។ ជនរងគ្រោះពីការជួញដូរមនុស្សទាំងអស់ដែលត្រូវបានរកឃើញនៅទូទាំងពិភពលោក មានស្ត្រី និងក្មេងស្រីមានចំនួន ៧១ភាគរយ ដែលកុមារីជិតបីនាក់ក្នុងចំណោមកុមាររងគ្រោះបួននាក់ដោយការជួញដូរ ហើយប្រហែលជាបីនាក់ក្នុងចំនោមស្ត្រីនិងក្មេងស្រី ត្រូវបានគេជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ[84]។ ហើយមានក្មេងស្រីប្រមាណ ១២០ លាននាក់នៅទូទាំងពិភពលោក (ច្រើនជាង ១ នាក់ក្នុងចំណោម ១០ នាក់) បានឆ្លងកាត់ការរួមភេទដោយបង្ខំ ឬការរួមភេទដោយបង្ខំផ្សេងទៀត កំឡុងពេលណាមួយក្នុងជីវិតរបស់ពួកគេ[85]។

សំខាន់ជាងនេះទៅទៀតនោះ អំពើហិង្សាលើស្ត្រី និងក្មេងស្រី ធ្វើឲ្យក្មេងស្រី និងស្ត្រីវ័យជំទង់ប្រឈមមុខនឹងហានិភ័យខ្ពស់[86]។ បញ្ហានេះ ត្រូវបានលើកមកដាក់ជួរមុខនៃការជជែកវែកញែកអំពីសិទ្ធិមនុស្សជាសកល តាមរយៈកិច្ចខិតខំប្រឹងប្រែងពីសំណាក់អង្គការអន្តរជាតិ ចលនារបស់ស្ត្រី រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗ[87]។ ធនាគារពិភពលោក ចាត់ទុកសិទ្ធិរបស់ស្ត្រីជាសិទ្ធិមនុស្ស ហើយក្នុងបរិបទនៃការអភិវឌ្ឍធនធានមនុស្ស រួមមានការបញ្ញាបយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ដែលជាមធ្យោបាយដ៏សំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍[88]។

## ១. និន្នាការ និងវឌ្ឍនភាព

### *១.១. អាស៊ាន (ASEAN)*

នៅក្នុងគោលការណ៍ណែនាំក្នុងតំបន់អាស៊ានឆ្នាំ២០១៧ ដែលមានទិន្នន័យពីប្រទេសចំនួនប្រាំបីក្នុងចំណោមសមាជិកទាំងដប់ អង្គការសុខភាពពិភពលោក និងការស្ទង់មតិដែលទាក់ទងទៅនឹងសុខភាព ហើយនឹងទិន្នន័យការស្ទង់មតិប្រជាសាស្ត្រ និងសុខភាព ចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រី ត្រូវបានប្រើដើម្បីវាស់អត្រារីករាលដាលនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី[89, p. 26]។ ទិន្នន័យបង្ហាញថាភាគរយរបស់ស្ត្រីដែលមានធ្លាប់រងអំពើហិង្សាពីដៃគូស្និតស្នាលមានចាប់ពី ៦ ភាគរយ នៅសិង្ហបុរីរហូតដល់ ៤៤ ភាគរយនៅប្រទេសថៃ(មើលក្រាហ្វិកទី១២)។ ទោះបីជា មានកិច្ចខំប្រឹងប្រែងក្នុងការប្រមូលទិន្នន័យ និងភស្តុតាងដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី ប៉ុន្តែទិន្នន័យពីសមាមាត្រស្ត្រីដែលធ្លាប់រងអំពើហិង្សាផ្លូវចិត្តពីដៃគូស្និទ្ធស្នាលនៅតែមានការខ្វះខាត។ ទោះបីជាយ៉ាងណាក៏ដោយ អត្រារីករាលដាលរបស់ស្ត្រី និងក្មេងស្រីដែលធ្លាប់រងអំពើហិង្សាលើផ្លូវកាយ និង/ឬក៏របួសផ្លូវចិត្ត គឺមានកម្រិតខ្ពស់នៅប្រទេសកម្ពុជា ឡាវ និងប្រទេសហ្វីលីពីន(មើលក្រាហ្វិកទី១៣)[89, p. 27] ។

*ក្រាហ្វិកទី១២៖សមាមាត្រស្ត្រីដែលធ្លាប់រងអំពើហិង្សាលើរាងកាយនិង / ឬអំពើហិង្សាផ្លូវភេទពីដៃគូជិតស្និទ្ធក្នុងជីវិតរបស់ពួកគេ ២០០៣-២០០៧*




ប្រភព៖ គោលការណ៍ណែនាំក្នុងតំបន់អាស៊ានស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ការប្រមូ លនិងប្រើប្រាស់ទិន្នន័យ ឆ្នាំ ២០១៨

*ក្រាហ្វិកទី១៣៖ សមាមាត្រស្ត្រី និងក្មេងស្រី ដែលបានរងរបួសទាក់ទងនឹងអំពើហិង្សា*




ប្រភព៖ គោលការណ៍ណែនាំក្នុងតំបន់អាស៊ានស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ការប្រមូ លនិងប្រើប្រាស់ទិន្នន័យឆ្នាំ ២០១៨

មានតែប្រទេសមួយចំនួនប៉ុណ្ណោះដែលមានទិន្នន័យអំពើហិង្សាផ្លូវភេទពីអ្នកក្រៅពីដៃគូដូចជា ប្រទេសឥណ្ឌូនេស៊ីដែលមានស្ត្រី ២៤ ភាគរយ ធ្លាប់រងអំពើហិង្សាលើរាងកាយ និង/ឬ អំពើហិង្សាផ្លូវភេទពីអ្នកក្រៅពីដៃគូរ និង ១៨ ភាគរយ ដោយដៃគូសិទ្ធស្នាលរបស់ពួកគេ ប្រទេសវៀតណាមមាន ២ ភាគរយធ្លាប់រងអំពើហិង្សាផ្លូវភេទពីផ្សេងក្រៅប្តីរបស់ពួកគេ និងឡាវ មានត្រឹមតែ ១ ភាគរយប៉ុណ្ណោះ[89, p. 26]។

### ១.២. ប្រទេសកម្ពុជា

ភាគរយនៃគ្រួសារដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារបានធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំ ហើយបានធ្លាក់ចុះស្ទើរតែពាក់កណ្តាលរវាងឆ្នាំ ២០១០ និងឆ្នាំ ២០១៧ ពី ១ ភាគរយទៅ ០,៥ ភាគរយ (មើលក្រាហ្វិកទី១៤) [90]។

*ក្រាហ្វិកទី១៤៖ សមាមាត្រស្ត្រី និងក្មេងស្រី ដែលបានរងរបួសទាក់ទងនឹងអំពើហិង្សា*




ប្រភព៖ អ្នកស្រាវជ្រាវបានបង្កើតចេញពី ទិន្នន័យឃុំ/សង្កាត់ឆ្នាំ ២០១០ - ២០១៧ ។

ទោះបីនិន្នាការនៃគ្រួសារដែលធ្លាប់ទទួលរងអំពើហិង្សាក្នុងគ្រួសារមានការថយចុះក៏ដោយ ក៏អំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅតែជាបញ្ហាសំខាន់ រួមជាមួយប្រភេទអំពើហិង្សាក្នុងគ្រួសារផ្សេងទៀត ដែលបណ្តាលមកពីវិសមភាពយេនឌ័រ និងបទដ្ឋានប្រពៃណីដែលមានស្រាប់នៅក្នុងបរិបទកម្ពុជា។ ជាលទ្ធផលស្ត្រីប្រមាណ ៥០ ភាគរយ បានគិតថាអំពើហិង្សាប្តីលើប្រពន្ធអាចទទួលយកបានប្រសិនបើភរិយាមានអាកប្បកិរិយាមិនគោរព ឈ្លោះប្រកែក ឬមិនស្តាប់បង្គាប់ប្តី[91]។ លើសពីនេះទៅទៀត មានបុរសជាង ៥៤ ភាគរយ បានរាយការណ៍ថា បានរំលោភបំពានខាងផ្លូវចិត្តដៃគូស្និទ្ធស្នាលក្នុងជីវិតរបស់ពួកគេ ហើយយ៉ាងហោចណាស់មានស្ត្រី ៤៨ ភាគរយ ដែលធ្លាប់រងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទ ដោយដៃគូស្និទ្ធស្នាលរងរបួស [89, p. 27]។

ករណីរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទនៅតែជាបញ្ហាចម្បងនៅកម្ពុជា ព្រោះថាចំនួនករណីរំលោភសេពសន្ថវៈលើអនីតិជននៅតែកើនឡើង។ ទោះបីជាយ៉ាងណា ភស្តុតាងដើម្បីវាយតម្លៃយ៉ាងច្បាស់អំពីទំហំ និងលក្ខណៈជាក់លាក់នៃអំពើហិង្សាផ្លូវភេទលើកុមារចាំបាច់ត្រូវតែប្រមូល។ ក្នុងឆ្នាំ ២០១១ ករណីរំលោភសេពសន្ថវៈលើកុមារមានចំនួន ៦៥៨ ករណី ត្រូវបានរាយការណ៍ទៅអង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងជនល្មើសចំនួន ៧៧០ នាក់[91]។ មានតែករណីរំលោភសេពសន្ថវៈ ចំនួន ៥៨ ភាគរយ ប៉ុណ្ណោះក្នុងចំណោម ២២៤ ករណីរំលោភសរុប និងការប៉ុនប៉ងរំលោភសេពសន្ថវៈបានរាយការណ៍ទៅ នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃ[91]។

## ២. បញ្ហាប្រឈម

គួរកត់សម្គាល់ដែរថា សមភាពយេនឌ័រ និងភាពចាំបាច់នៃការបញ្ជ្រាបយេនឌ័រត្រូវបានផ្តល់អាទិភាពនៅក្នុងរបៀបវារៈនយោបាយអាស៊ាន ហើយត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រ និងគោលនយោបាយជាតិសំខា

ន់ៗផងដែរ។ ប៉ុន្តែទោះយ៉ាងណា វិសមភាពយេនឌ័រក្នុងទម្រង់ជាអំពើហិង្សាលើស្ត្រីនៅតែកើតមាននៅក្នុងប្រទេសកម្ពុជា។ នៅពេលដែលប្រៀបធៀបជាមួយបណ្តាប្រទេសអាស៊ានផ្សេងទៀត ប្រទេសកម្ពុជាតែមានអត្រាខ្ពស់ ចំពោះស្ត្រីដែលធ្លាប់រងនូវអំពើហិង្សាលើរាងកាយ ឬផ្លូវភេទដោយដៃគូស្និទ្ធស្នាល ហើយបណ្តាលឲ្យរងរបួស[៩០]។ បញ្ហាប្រឈមនៃការលុបបំបាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅកម្ពុជា មានដូចខាងក្រោមនេះ៖

- **ខ្វះការយល់ដឹងអំពីអំណាចមិនស្មើគ្នារវាងបុរស និងស្ត្រី៖** កត្តាវប្បធម៌ និងរចនាសម្ព័ន្ធដែលទាក់ទងនឹងអំណាច និងការគ្រប់គ្រងក្នុងគ្រួសារ រួមទាំងការបែងចែកការងារយ៉ាងតឹងរឹងរវាងបុរស និងស្ត្រី នាំឲ្យមានការរើសអើងទាក់ទងនឹងភេទ ដែលជាបុព្វហេតុចម្បងនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ បទដ្ឋានវប្បធម៌និងជំនឿប្រពៃណីនៅតែចាក់ឫសយ៉ាងជ្រៅនៅក្នុងគ្រួសារខ្មែរជាច្រើន ដែលនាំឲ្យមានជំនឿថាបុរសត្រូវបានអនុញ្ញាតឲ្យគ្រប់គ្រងលើស្ត្រី និងធ្វើជាមេគ្រួសារ[78]។ កត្តាសំខាន់ៗដែលរួមចំណែកដល់ អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជាគឺ៖ ការសេពគ្រឿងស្រវឹងច្រើនដោយដៃគូរបស់ស្ត្រី ការគ្រប់គ្រងអាកប្បកិរិយាក្នុងអាពាហ៍ពិពាហ៍ មានកូនច្រើនក្នុងបន្ទុក ស្ត្រីដែលប្រវត្តរងអំហិង្សាក្នុងគ្រួសារកាលពីកុមារភាព រួមទាំងកម្រិតនៃការអប់រំទាបរបស់ស្ត្រី និងដៃគូរបស់គាត់ [92]។ កត្តាចូលរួមចំណែកសំខាន់ៗផ្សេងទៀត គឺបទដ្ឋាន និងការរំពឹងទុកសង្គម។ មានប្រជាជនស្ទើរតែ ៣០ ភាគរយ នៃការស្ទង់មតិជឿថា អំពើហិង្សាលើស្ត្រីអាចទទួលយកបានពីសំណាក់ប្តីវាយប្រពន្ធរបស់គាត់[93, 94]។
- **ឥរិយាបថរបស់ស្ត្រីចំពោះដំណើរការតុលាការ៖** ទោះបីជាមានវិធានការណ៍ការពារដែលមានចែងនៅក្នុងច្បាប់ ជាពិសេសក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ជនរងគ្រោះ ជាពិសេសស្ត្រីមិនជ្រើសរើសដើម្បីស្វែងរកការការពារដែលត្រូវបានផ្តល់ជូននោះទេ។ ដោយសាតែ សេវាកម្មមិនត្រូវបានផ្តល់ឲ្យបានទូលំទូលាយនៅទូទាំងប្រទេសនោះទេ ហើយសេវាកម្មមិនអាចទទួលបានគ្រប់ស្ត្រីរងគ្រោះទាំងអស់[91]។ លើសពីនេះទៅទៀត ជំនឿ និងការយល់ឃើញបែបប្រពៃណីទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាពីសំណាក់ដៃគូស្និទ្ធស្នាលនៅតែត្រូវបានគេចាត់ទុកថាជាបញ្ហាក្នុងគ្រួសារ។ ដូច្នេះជនរងគ្រោះខ្លះមិនបានប្តឹងទៅនគរបាល ឬអាជ្ញាធរមូលដ្ឋាននោះទេ។ ទន្ទឹមនឹងផងដែរ ស្ត្រីដែលទទួលរងអំពើហិង្សាជាញឹកញាប់ខ្វះមធ្យោបាយធ្វើដំណើរដើម្បីទទួលបានសេវាកម្មច្បាប់[91]។
- **ខ្វះការយល់ដឹងពីច្បាប់៖** ប្រទេសកម្ពុជាមានច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការការពារជនរងគ្រោះដែលហៅថា «ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ» ដែលជម្រុញឲ្យស្ត្រីដាក់ពាក្យបណ្តឹងដើម្បីរកយុត្តិធម៌ប្រសិនបើពួកគេទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ។ ទោះយ៉ាងណាក៏ដោយ មានករណីដ៏កម្រស្ត្រីប្តឹងដៃគូរបស់ពួកគេដោយសារតែពួកគេមិនយល់ពីគោលបំណងនៃច្បាប់។ ទោះបីមានការខិតខំប្រឹងប្រែងគួឲ្យកត់សម្គាល់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយព័ត៌មានយ៉ាងណាក៏ដោយ ក៏នៅតែមិនមានលក្ខណៈគ្រប់គ្រាន់ទាំងគុណភាព និងបរិមាណ[95]។

## ៣. ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

### *៣.១ អាស៊ាន (ASEAN)*

ចាប់តាំងពីអំពើហិង្សាលើស្ត្រី និង ក្មេងស្រីជាបញ្ហាចម្បងនៅក្នុងសកល ព្រមទាំងកម្រិតអាស៊ាន និងការអនុម័តរបស់អង្គការសហប្រជាជាតិលើសេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី និងកុមារ អាស៊ានបានប្តេជ្ញាចាត់វិធានការសមស្របដើម្បីការពារ និងឆ្លើយតបចំពោះរាល់ទម្រង់ទាំងឡាយនៃអំពើហិង្សាលើស្ត្រី[96]។ លើសពីនេះទៅទៀត ប្រទេសដែលជាសមាជិកអាស៊ានភាគច្រើនបានបង្កើតច្បាប់ជាតិសម្រាប់អំពើហិង្សាលើស្ត្រី និង/ឬ អំពើហិង្សាក្នុងគ្រួសារ ហើយប្រទេសដែលជាសមាជិកមួយចំនួនបានបង្កើតផែនការសកម្មភាពជាតិដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ និងគោលនយោបាយរបស់ខ្លួន។ រដ្ឋាភិបាល និង/ឬសង្គមស៊ីវិលបានផ្តល់នូវសេវាកម្មដល់ស្ត្រី និងក្មេងស្រីដែលធ្លាប់ជួបប្រទះនឹងអំពើហិង្សា ដែលមានដូចជា កន្លែងស្នាក់អាស្រ័យ បណ្តាញទូរស័ព្ទបន្ទាន់ មជ្ឈមណ្ឌលច្រកចេញចូលតែមួយសម្រាប់ស្ត្រី និងកុមារនៅតាមប៉ុស្តិ៍ប៉ូលីសដែលមាននៅតាមប្រទេសភាគច្រើន។ ប្រទេសជាច្រើនក៏បានអនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹងដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រីផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការអនុវត្តមិនដូចគ្នានឹងទម្រង់អំពើហិង្សាលើស្ត្រីមួយចំនួន ដូចជាការរំលោភសេពសន្ថវៈក្នុងជីវិតអាពាហ៍ពិពាហ៍ និងអំពើហិង្សាផ្លូវភេទដ៏ទៃទៀតដែលមិនមានចែងនៅក្នុងច្បាប់បច្ចុប្បន្ន។ ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ និងការផ្តល់សេវាគាំទ្រផ្នែកច្បាប់ ព្រមទាំងការរើសអើងបទដ្ឋាន និងបរិបថយេនឌ័រ ដែលបណ្តាលឲ្យមានអំពើហិង្សាលើស្ត្រី ចំនុចដែលនៅតែទាមទារឲ្យមានការយកចិត្តទុកដាក់បន្ថែមទៀត មានដូចជាគម្លាតទិន្នន័យស្តីពីវិសាលភាព ព្រមទាំងផលប៉ះពាល់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ហើយធនធានហិរញ្ញវត្ថុ និងធនធានមនុស្សនៅមានកំណត់។ ជាពិសេស សង្កត់ធ្ងន់លើគំនិតផ្តួចផ្តើមរបស់ប្រទេសសមាជិកអាស៊ាន ដែលមាននៅក្នុងផ្នែកទី ២ នៃផែនការសកម្មភាពអាស៊ាន[96]។

### *៣.២ ប្រទេសកម្ពុជា*

ការដោះស្រាយអំពើហិង្សាក្នុងគ្រួសារនៅប្រទេសកម្ពុជាបានវិវឌ្ឍន៍ទៅមុខ តាមរយៈការផ្តួចផ្តើមគំនិតបង្កើតច្បាប់ ផែនការសកម្មភាពជាតិ កម្មវិធីអប់រំ និងការបង្កើតធនធានសម្រាប់ការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសារ។ ក្រសួងកិច្ចការនារីបានដឹកនាំកម្មវិធីអប់រំដែលមានគោលបំណងកាត់បន្ថយ និងលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ។ ដើម្បីឲ្យមានការអនុវត្តគម្រោងដែលផ្តោតសំខាន់លើការអប់រំ និងផ្តល់សេវាកម្មដើម្បីដោះស្រាយបញ្ហានេះ ក្រសួងបានសហការជាមួយអង្គការមួយចំនួនដូចជា អង្គការសហប្រជាជាតិស្ត្រី (UN Women) អង្គការឃែរ (CARE) កិច្ចសហប្រតិបត្តិការអាលឺម្ម៉ង់ (GIZ) [93]។

អង្គការសហប្រជាជាតិ បានឯកភាពជាលក្ខណៈពហុភាគីលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) បានធ្វើឲ្យប្រសើរឡើងដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០០៤។ ការបន្ថែមសូចនាករចំនួនបួននៅក្នុងផែនការអភិវឌ្ឍន៍ជាតិរបស់ខ្លួនសម្រាប់គោលដៅត្រួតពិនិត្យដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រីត្រូវបានបង្កើតឡើង ដើម្បីកាត់បន្ថយរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងកុមារនៅឆ្នាំ ២០១៥[97]។ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ២០២៣ (SDGs)ចូលរួមលុបបំបាត់អំពើហិង្សាលើស្ត្រី តាមរយៈការចូលរួមរបស់បុរស និងក្មេងប្រុស។

លើសពីនេះរាជរដ្ឋាភិបាលកម្ពុជា ក៏បានអនុម័តផងដែរនូវក្របខ័ណ្ឌច្បាប់ ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីដូចខាងក្រោម៖

- **ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ បានកំណត់អំពើហិង្សាលើស្ត្រីជា** «(១)អំពើដែលអាចប៉ះពាល់ដល់អាយុជីវិត (រួមទាំងការគិតទុកជាមុន ការសម្លាប់មនុស្សដោយចេតនា ឬដោយអចេតនា) (២)អំពើដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរដល់រាងកាយ (រួមទាំងអំពើហិង្សាលើរាងកាយដែលអាចបណ្តាលឲ្យមាន ឬគ្មានស្នាមរបួស) (៣)រាល់ការប្រព្រឹត្តដោយទារុណកម្ម ឬអំពើឃោរឃៅណាមួយ (រួមទាំងការយាយីដែលបណ្តាលឲ្យមានគ្រោះថ្នាក់ខាងផ្លូវចិត្ត ផ្លូវអារម្មណ៍ ឬបញ្ញា ដែលគំរាមកំហែងដល់មនុស្សក្នុងគ្រួសារ) ឬ (៤)ការរំលោភបំពានផ្លូវភេទ (រួមទាំងការរំលោភសេពសន្ថវៈ ការរំខានយាយីផ្លូវភេទ ឬការប៉ះពាល់ដោយមិនសមរម្យ)»[98]។
- **បទប្បញ្ញត្តិទូទៅសម្រាប់ការអនុវត្តច្បាប់ព្រហ្មទណ្ឌរួមមានមាត្រាចំនួនពីរដែលអាចអនុវត្តករណីអំពើហិង្សាក្នុងគ្រួសារ៖** មាត្រាទី២៧ «អំពើហិង្សាដោយចេតនាលើមនុស្សណាម្នាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២ លានរៀលទៅ ៦ លានរៀល»[99]។
- **ផែនការសកម្មភាពជាតិ ដើម្បីការពារអំពើហិង្សាលើស្ត្រី២០០៩-២០១៤** ផ្តល់អាទិភាពដល់ការដោះស្រាយលើហានិភ័យដែលបានកើនឡើងដោយអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទ ព្រមទាំងអំពើហិង្សាលើស្ត្រី។ ហានិភ័យដែលបានកើនឡើង សម្តៅលើស្ត្រីដែលងាយរងគ្រោះ ដោយសារតែបាត់បង់ឱកាសនៅក្នុងសង្គម។ យុទ្ធសាស្ត្រខាងក្រោមត្រូវបានដាក់លម្អិតនៅក្នុងផែនការនេះ៖ ការទប់ស្កាត់ជាបឋម (ការទប់ស្កាត់មុនពេលអំពើហិង្សាក្នុងគ្រួសារកើតមានឡើង) ពង្រីកការទប់ស្កាត់ផ្នែកច្បាប់ និងសេវាកម្មពហុវិស័យ ការរៀបចំ និងការអនុវត្តគោលនយោបាយ និងច្បាប់ស្តីពីការពង្រឹងសមត្ថភាពព្រមទាំងការពិនិត្យ តាមដាន និងវាយតម្លៃ[91]។
- **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០០៩-២០១៣** បានកំណត់បញ្ហាអាទិភាពចំនួន ១១ បញ្ហាមួយក្នុងចំណោមនោះគឺច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ។ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា - ព្រឹទ្ធសភា និងអធិការកិច្ច (MONASRI) មានកម្មវិធីចំនួន ប្រាំ ទាក់ទងនឹងបញ្ហានេះផងដែរ៖ « (i)ការផ្សព្វផ្សាយច្បាប់ (ii)អធិការកិច្ច (iii)ការតាមដានការអនុវត្តច្បាប់ (iv)ការដោះស្រាយពាក្យបណ្តឹង និង (v)ការពង្រឹងស្ថាប័ន និងការអភិវឌ្ឍសមត្ថភាព រួមទាំងការលើកកម្ពស់យេនឌ័រនៅក្នុងកម្មវិធីអាទិភាពចំនួនប្រាំ»[46]។ រាជរដ្ឋាភិបាលបានកត់សម្គាល់ពីវឌ្ឍនភាពក្នុងការដោះស្រាយអំពើហិង្សាលើស្ត្រី ប៉ុន្តែក៏សង្កត់ធ្ងន់លើតម្រូវការក្នុងការបង្កើនកញ្ចប់ថវិកាសម្រាប់ជនរងគ្រោះដែលរងអំពើហិង្សាក្នុងគ្រួសារផងដែរ។
- **ច្បាប់រៀបចំអង្គការ វិមជ្ឈការ និងវិសហមជ្ឈការឆ្នាំ២០០៩** ធ្វើឲ្យមានការសម្របសម្រួលតាមរយៈខ្សែបណ្តោយកាន់តែច្រើនឡើងជាមួយក្រសួងពាក់ព័ន្ធ ដោយមានគោលបំណងលើកកម្ពស់ការផ្តល់សេវាសង្គមថ្នាក់មូលដ្ឋាន ដូចជាគណៈកម្មាធិការស្ត្រី និងកុមារជាដើម[100]។

- **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី III** បានបញ្ជាក់ជាពិសេសពីស្ត្រី សមភាពយេនឌ័រ និងការកាត់បន្ថយអំពើហិង្សាលើស្ត្រីជាសកល (អង្គការមិនមែនរដ្ឋាភិបាល-អនុសញ្ញាស៊ីដ CEDAW ឆ្នាំ ២០១១)។ យុទ្ធសាស្ត្រចតុកោណជាបន្តបន្ទាប់សម្រាប់ កំណើន ការងារ សមធម៌ និងប្រសិទ្ធភាពដំណាក់កាលទីIV (២០១៨-២០២៣) បានសន្យាបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីឲ្យមានការចូលរួមរបស់ស្ត្រីក្នុងតំណែងជាអ្នកដឹកនាំនៅក្នុងក្រសួងពាក់ព័ន្ធ និង«ការលើកកម្ពស់ការអនុវត្តផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី» ក៏ដូចជាជម្រុញវប្បធម៌អហិង្សា [32]។
- **ផែនការយុទ្ធសាស្ត្រនារីរតនៈដំណាក់កាលទីIV(២០១៤-២០១៨)គឺជាផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំ** សម្រាប់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី។ ផែនការនេះពាក់ព័ន្ធនឹងការដាក់ចេញនូវតួនាទីសំខាន់បំផុតរបស់ក្រសួង ដែលធ្វើការជាមួយរាជរដ្ឋាភិបាលដើម្បីវាយតម្លៃ កំណែទម្រង់ និងអនុវត្តគោលនយោបាយដែលទាក់ទងទៅនឹងសមភាពយេនឌ័ររួមទាំងគោលនយោបាយអំពើហិង្សាក្នុងគ្រួសារ ។

លើសពីនេះទៀត ប្រទេសកម្ពុជាបានអនុម័តកិច្ចព្រមព្រៀងអន្តរជាតិមួយចំនួន និងបានចុះហត្ថលេខីលើសេចក្តីប្រកាសអន្តរជាតិជាច្រើនទាក់ទងនឹងអំពើហិង្សាលើស្ត្រី និងកុមារ។ សេចក្តីប្រកាសអន្តរជាតិទាំងនេះផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តច្បាប់ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងដោះស្រាយតម្រូវការ ហើយនឹងបញ្ជាកង្វល់របស់ស្ត្រីដែលត្រូវបានគេរំលោភបំពាន។

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (១៩៤៨)[101]
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (១៩៧៩)[102]
- សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី (៩៩៣)[103]
- សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច(២០០៧)[104]
- ដំណោះស្រាយរបស់ក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ ១៣២៥[105], ១៨២០[106] និង១៨៨៨ [107]ទាក់ទងនឹងស្ត្រី សន្តិភាព និងសន្តិសុខ។

### *៣.៣ គម្លាតគោលនយោបាយនៅកម្ពុជា*

មានចំណុចខ្វះខាតមួយចំនួននៅក្នុងការអនុវត្តច្បាប់អំពើហិង្សាក្នុងគ្រួសារ និងការអនុវត្តគោលនយោបាយនៅក្នុងប្រទេសកម្ពុជា៖

- ច្បាប់ឆ្នាំ ២០០៥ ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះបច្ចុប្បន្នមិនត្រូវបានអនុវត្តឲ្យស្របតាមស៊ីដរ[93, 94]។ ហើយពាក្យពេជ្រក្នុងច្បាប់មិនមានទំនាក់ទំនងផ្ទាល់រវាងវិធានការដាក់ទណ្ឌកម្ម និងគោលនយោបាយនោះទេ។ នៅខ្វះភាពច្បាស់លាស់នៃអ្វីដែលបង្កើតជាបទមជ្ឈឹមតូចតាច និងបទមជ្ឈិមអនីតិជនធំ ដែលសំខាន់ពីព្រោះបទមជ្ឈឹមតូចតាចមិនបានប្រើប្រាស់ក្រមព្រហ្មទណ្ឌនោះ [98, 99]។

- ក្រសួងកិច្ចការនារី គឺជាក្រសួងនាំមុខក្នុងការដោះស្រាយបញ្ហាអំពើហិង្សាលើស្ត្រី ប៉ុន្តែមានធនធានមិនគ្រប់គ្រាន់ និងយន្តការត្រួតពិនិត្យដើម្បីអនុវត្តគោលនយោបាយ។ ក្រសួងផ្សេងទៀតនិងអាចចូលរួមក្នុងដំណើរការអនុវត្តន៍គោលនយោបាយប៉ុន្តែតួនាទីរបស់ពួកគេខ្វះភាពច្បាស់លាស់និងទំនួលខុសត្រូវច្បាស់លាស់ [95, 108]។
- ការបែងចែកថវិការបស់រដ្ឋាភិបាលជាធម្មតាច្រើនតែផ្តល់ដល់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍអាជីវកម្មជាជាងសេវាកម្មសង្គម។ កម្មវិធីសេវាកម្មសង្គមជារឿយៗជួបប្រទះនូវការពន្យារពេលក្នុងការចំណាយមូលនិធិ ការផ្លាស់ប្តូរបុគ្គលិកញឹកញាប់ និងគ្រប់គ្រងការព្យាករណ៍ថវិកាមិនត្រឹមត្រូវសម្រាប់កម្មវិធីដែលសកម្មភាពមិនត្រូវគ្នានឹងការចំណាយ[108]។
- ឥរិយាបថវប្បធម៌ និងជំនឿសង្គមអំពីបទដ្ឋានយេនឌ័រ ហើយនឹងមនោគមវិជ្ជាយេនឌ័រ ដែលមានលក្ខណៈស្តង់ដានៅជុំវិញច្បាប់ប្រុស (បុរស) និងច្បាប់ស្រី (ស្ត្រី)[109] ។ ការស្ទង់មតិអំពីអំពើហិង្សាលើស្ត្រីឆ្នាំ២០០៩ បានង្ហាញថា «ការទទួលយក ការអត់ឱន និងភាពសមហេតុផលនៃការរំលោភបំពានបែបនេះ គឺចាក់ឫសយ៉ាងជ្រៅទៅក្នុងប្រព័ន្ធតម្លៃសង្គមបែបប្រពៃណី ដែលគួតែសិក្សាបន្ថែមទៀត»[93]។ ស្ទើរតែពាក់កណ្តាលនៃស្ត្រីដែលត្រូវបានស្ទង់មតិនៅក្នុងស្ថិតិអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា (CDHS) បានបង្ហាញថាយ៉ាងហោចណាស់ មានហេតុផលមួយដែលពួកគេជឿថាប្តីអាចធ្វើបាបប្រពន្ធរបស់គាត់ ហើយបុរស ២៧ ភាគរយ បានទទួលស្គាល់ថា ករណីដែលប្តីវាយប្រពន្ធរបស់ខ្លួនអាចទទួលយកបាន[78]។ តួនាទីយេនឌ័របែបប្រពៃណីនៅតែមាននៅក្នុងប្រព័ន្ធផ្សព្វផ្សាយ [78, 94]។ ល័ក្ខខ័ណ្ឌវប្បធម៌ទាំងនេះហើយង អាចបង្ហាញពីការលំបាកក្នុងការអនុវត្តច្បាប់អំពើហិង្សាក្នុងគ្រួសារ។

## ៤. អ្វីដែលគួរធ្វើបន្ត

- ការផ្ទេរកម្មវិធីអប់រំពី ច្បាប់អំពើហិង្សាក្នុងគ្រួសារ ទៅឲ្យក្រសួងអប់រំយុវជន និងកីឡា ជាអ្នកទទួលខុសត្រូវ រីឯក្រសួងកិច្ចការនារីទទួលបន្ទុកការត្រួតពិនិត្យ និងការភ្ជាប់ស្ត្រីទៅនឹងធនធាន [110]។
- រាជរដ្ឋាភិបាល អាចពង្រឹងថវិកាជាតិដែលបានវិភាជទៅក្រសួងកិច្ចការនារី និងក្រសួងអប់រំដើម្បីជាអាទិភាពដល់ការទប់ស្កាត់អំពើហិង្សា។ ដូច្នេះការចំណាយលើការបណ្តុះបណ្តាល ការឆ្លើយតបនឹងគ្រោះថ្នាក់ពីអំពើហិង្សា សេវាច្បាប់ តុលាការ កម្មវិធីនានា ព្រមទាំងសម្ភារៈអប់រំគួតែរាប់បញ្ចូលតាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ [110]
- ការសម្របសម្រួល បន្ថែមទៀតក្នុងចំណោមអាជ្ញាធរថ្នាក់ជាតិ ខេត្ត និងស្រុក ហើយផ្តល់ភាពងាយស្រួលដល់ការកេនូវសម្ភារៈអប់រំ ការបណ្តុះបណ្តាល ការធ្វើបច្ចុប្បន្នភាពព័ត៌មានដោយមានទំនួលខុសត្រូវច្បាស់លាស់សម្រាប់តួនាទីរបស់ក្រសួងនីមួយៗក្នុងការអនុវត្តគោលនយោបាយអំពើហិង្សាក្នុងគ្រួសារ។ បញ្ហានេះអាចត្រូវបានរាយការណ៍ និងត្រួតពិនិត្យដោយក្រសួងកិច្ចការនារី [110]

- ធ្វើឲ្យប្រសើរឡើងនូវការអប់រំតាមរយៈផ្តល់ការបណ្តុះបណ្តាលឲ្យកាន់តែទូលំទូលាយ និងពង្រឹងវប្បធម៌ការងារ អាជ្ញាធរ និងមន្ត្រីរដ្ឋាភិបាលមូលដ្ឋាន។ ការបណ្តុះបណ្តាលគួរតែរួមបញ្ចូលនូវព័ត៌មានអំពីវិធីសាស្ត្រក្នុងការសម្គាល់នូវសញ្ញានៃអំពើហិង្សាក្នុងគ្រួសារដែលអាចនឹងកើតមានឡើង របៀបទុបស្កាត់ និងរបៀបដែលបុគ្គលម្នាក់ៗអាចជួយជនរងគ្រោះបាន។ ការបណ្តុះបណ្តាលអាចផ្សព្វផ្សាយដល់ក្រសួងដែលពាក់ព័ន្ធ ហើយបញ្ជូនបន្តទៅថ្នាក់ស្រុក [93, 109]
- ពង្រីកការអប់រំ និងកម្មវិធីសហគមន៍ ដើម្បីឲ្យបុរសចូលរួមក្នុងការតស៊ូមតិសម្រាប់ស្ត្រី និងកែប្រែគំនិតចាស់គំរិលទាក់ទងនឹងយេនឌ័រ[111]។ ក្រុមសុវត្ថិភាពសុខភាពភូមិ ព្រមទាំងក្រុមស្ត្រី និងបុរសអាចប្រើប្រាស់សម្ភារៈដែលផ្តល់ដោយអង្គការសេវាសហគមន៍(CSOs) ដើម្បីពង្រីកដល់សហគមន៍ [80].
- បង្កើតប្រព័ន្ធប្រមូលទិន្នន័យតាមប្រព័ន្ធស្តង់ដារ ដែលតាមដានរាល់ការរាយការណ៍ ពីអំពើហិង្សាក្នុងគ្រួសារ ដែលមាននៅគ្រប់អាជ្ញាធរពាក់ព័ន្ធ[82, 93, 112]
- បន្តពង្រីកនូវតួនាទីស្ត្រីនៅក្នុងរដ្ឋាភិបាល ប្រព័ន្ធយុត្តិធម៌ និងសេដ្ឋកិច្ច តាមរយៈកម្មវិធីបញ្ជ្រាបយេនឌ័រ [88, 113]។
- ចូលរួមភាពជាដៃគូក្នុងអាស៊ានជាមួយទីភ្នាក់ងាររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិនានាដើម្បីបង្កើតការស្រាវជ្រាវបន្ថែមជាក់លាក់តាមតំបន់ ការវាយតម្លៃដែលល្អបំផុត លើការធ្វើអន្តរាគមន៍ទុបស្កាត់ និងវឌ្ឍនភាព[93, 109, 114]។

## សេចក្តីសន្និដ្ឋាន

